ភាគទី៣៦

សម្រែកតក់ស្លុតលាន់ឮទ្រហឹងអឺងអាប់ កងការពារទាំងប៉ុន្មានរត់ប្រសាចមកគ្រាថៅហ្វាយដោយវិប្បដិសារី។

-អ្នកប្រុស!? អ្នកប្រុសយ៉ាងម៉េចហើយ?

រាមនរិន្ទទប់ការឈឺចាប់បន្លឺខ្សាវៗ៖

-នាំឱម៉ាត្រលប់ទៅវិញ!

ឱម៉ាឈរសម្លឹងរាមនរិន្ទដែលត្រូវបានកូនថៅគ្រាចាកចេញទៅ នាងមិននិយាយស្តីតែនាងកំពុងតក់ស្លុត។ នាយគង់សម្លក់នាងខ្លែរ គេសន្ធាប់មកកាន់នាងខ្លាំងៗ៖

-ដឹងមកពីណា ថាអ្នកប្រុសឲ្យនាងទៅមេកុលសម្ព័ន្ធ?

ឱម៉ាយំអណ្តឹតអណ្តក ៖

- បងគង់! ខ្ញុំឮផ្ទាល់ត្រចៀក ឃើញផ្ទាល់ភ្នែក! គេហ៍ប្រគល់ខ្ញុំជាថ្នូរជាមួយស៊ីញេលើកិច្ចសន្យារបស់គេ!

អង្គរក្សរូបនោះមិនព្រមអាណិតគេ រឹតតែគំហកដាក់នាងខ្លាំងៗ ៖

-បើមែន ម៉េចក៏អ្នកប្រុសសម្រេចចិត្តចេញពីស្រុកសាមីស្អែកនេះ? អ្នកប្រុសរកឃើញឥន្ទប្បដិមាហើយនៅតែមិនយក! ឥឡូវនេះមករងគ្រាប់ឲ្យនាងទៀត នាងចេះគិតខ្លះទេ ?...

ជននោះអូសដៃឱម៉ាត្រណាត់ត្រណែងដោយខឹងសម្បារ។ នាងត្រូវគេនាំចេញពីព្រៃ ហើយរុញបញ្ចូលក្នុងរថយន្តដែលឈប់ចាំក្បែរមាត់ផ្លូវជាស្រេច។ រថយន្តចេញដំណើរត្រឡប់មកផ្ទះសំណាក់វិញ ដោយមានមនុស្សជំនិតរបស់រាមនរិន្ទអង្គុយក្បែរផង។ នៅចប់តាមផ្លូវ នាយអង្គរក្សខ្ពស់ស្រាវឥតមានស្តីរកឱម៉ាសូម្បីមួយម៉ាត់។ តរុណីដឹងថាគេកំពុងខឹងនាងខ្លាំង តែនាងទប់ស្មារតីឲ្យបាននឹងនរជាងមុន នាងប្រឹងសួរទៅកាន់គេ៖

- បងរឿន! លោក... ប្រុសរាម... ចេញពីភូមិភូរីខាន់វិញស្អែកនេះអ្ហេស៎ ?..

មនុស្សជំនិតរបស់នរិន្ទជៀងភ្នែកមករកនាងទាំងភាពមួហ្មងពុំទាន់រលាយបាត់អស់ពីផ្ទៃមុខនៅឡើយទេ។ គេពោលតប៖

-ដោយសារតែនាងកេតឌីម៉ា! អ្នកប្រុសលុបចោលគម្រោងការណ៍ដែលចង់បានឥន្ទប្បដិមាពីដៃអូណ៉រ! ខ្ញុំកំពុងឆ្ងល់ថា ដូចនាងអញ្ចឹងសមឲ្យអ្នកប្រុសមកស្រលាញ់ហើយមកលះបង់ថ្នាក់ហ្នឹងទេ?

ឌីម៉ាឱនមុខជ្រប់ នាងប្រទះឃើញស្នាមឈាមនៅប្រឡាក់ជាប់ម្រាមដៃខ្លះរបស់ខ្លួននៅឡើយ តរុណីលើកប្រអប់ដៃ ដែលប្រឡាក់ឈាមក្រហមឆ្អៅនៅឡើយនោះមកពិនិត្យដោយញាប់ញ័ររន្ធត់។ ទើបនាងងើបមុខសម្លឹងមនុស្សជំនិតរបស់រាមនរិន្ទសាជាថ្មី ម្តងណេះនាងសង្កេតឃើញយ៉ាងច្បាស់ថាក្រៅពីមានកំហឹងពេញផ្ទៃមុខក្នុងនោះគេក៏មានលាយឡំនូវក្តីបារម្ភដោយភក្តីភាពចំពោះចៅហ្វាយប្រុសផងដែរ ។

នាងនៅស្ងៀមលែងហ៊ានចេញវាចាទៅរកគេ ប៉ុន្តែក្នុងចិត្តកំពុងក្តុកក្តួលរកពណ៌នាមិនត្រូវ។

មកដល់ផ្ទះសំណាក់ នាងត្រូវបានគេរុញចូលបន្ទប់ដោយមានអ្នកយាមពីក្រៅ។ តាមរយៈទ្វារដែលបិទមិនទាន់ជិត ឌីម៉ាអាចមើលឃើញថាកូនចៅក្រោមបង្គាប់របស់រាមនរិន្ទដើរខ្វាត់ខ្វែងចុះឡើងកាត់តាមមុខបន្ទប់សំដៅបន្ទប់ចៅហ្វាយប្រុសដែលនៅក្បែរនោះ។

រូបរាងពេទ្យពីរនាក់ ដែលឈានប្រញាប់ប្រញាល់កាត់ពីមុខទ្វារបន្ទប់ ហាក់ដាស់សតិតរុណីឲ្យភ្ញាក់ដូចគេកន្ត្រាក់សាជាថ្មី។ នាងនឹកទៅដល់ស្ថានភាពរបស់រាមនរិន្ទ សេចក្តីឈឺចាប់  ការសង្ស័យ និងភាពភ័យខ្លាចទាំងអំបាលម៉ាន ហាក់រសាត់បាត់ពីរាងកាយបន្តិចម្តងៗ រហូតអស់រលីង ទាំងរឿងប្តូរខ្លួនជាមួយហត្ថលេខាមេកុលសម្ព័ន្ធនោះ ទាំងរឿងវង្វេងក្នុងព្រៃជ្រៅ ទាំងរឿងដែលចង់គេចទៅ Jayapuraវិញ។ អ្វីដែលនៅសល់ពេលនេះ គឺមានតែអារម្មណ៍ពុះកញ្ជ្រោលដែលចង់ដឹងថា រាមនរិន្ទ យ៉ាងណាទៅហើយ។

តរុណីស្ទុះរឹងចេញពីបន្ទប់ តែត្រូវកងការពារពីរនាក់ឃាត់ជាប់នៅមាត់ទ្វារ។ នាងជ្រួញចិញ្ចើមទាំងប្រឫកប្របល់ចិត្ត ហើយពោលទៅកាន់ពួកគេលែងគិតអៀនខ្មាស ៖

- គាត់! គាត់យ៉ាងម៉េចហើយបង? កុំឃាត់ខ្ញុំណ៎ា ខ្ញុំទៅមើលគាត់! ខ្ញុំចង់ទៅជួបគាត់!

កងការពារទាំងពីរបង្ហាញទឹកមុខមាំមិនសប្បាយចិត្ត ខុសប្លែកពីពេលមុនៗដែលគេធ្លាប់តែឱនលំទោនចំពោះនាង។ ឌីម៉ានឹកគិតស្ងាត់ៗក្នុងចិត្ត៖

- យើងបានធ្វើខុសចំពោះរាមនរិន្ទ មែនទេដឹង? គាត់ពិតជាមិនព្រមប្រគល់យើងទៅឲ្យមេកុលសម្ព័ន្ធ ដូចពាក្យរបស់មនុស្សជំនិតឈ្មោះ រឿន មែនទេដឹង? យើងសង្ស័យគាត់ខុសឬអ្វី ?

សំឡេងកងការពារម្នាក់ ពោលមកកាន់នាងហាក់មិនពេញចិត្ត ៖

- ពេទ្យកំពុងសង្គ្រោះអ្នកប្រុស! កុំមកចង់បង្ករឿងទៀត!

ស្រស់ស្រីក្ដុកក្ដួលចិត្តនិមិត្តតែឮពាក្យសង្គ្រោះដែលចេញពីបបូរមាត់កងការពារ នាងងាកសម្លឹងទៅរកបន្ទប់ធ្វើការរបស់រាមនរិន្ទ ដែលនៅទីនោះអង្គរក្សរឿន និងកងការពារពីរបីនាក់ទៀតកំពុងឆ្លេឆ្លាដោយការឈឺឆ្អាលចំពោះចៅហ្វាយ។

ក្នុងកាយវិការមួយហ្មង សំឡេងកងការពារដដែលលាន់ឡើងទន្ទឹមនឹងពេលដែលគេលូកដៃមករុញនារីឲ្យចូលទៅក្នុងបន្ទប់នាងវិញ។៖

- ចាក់អ្នកប្រុសឲ្យរបួសហើយ ចង់មកធ្វើល្អ ធ្វើជាឈឺឆ្អាលអី?

ទ្វារត្រូវបិទគ្រឹប ទោះអង្វរយ៉ាងណាក៏លែងរបើកហើយ។ ឪម៉ាដាក់បង្គុយយឺតៗទៅផ្ទាល់នឹងឥដ្ឋក្បែរទ្វារទាំងហេងហាងពេញក្នុងចិត្ត។ នាងឈ្ងោកសម្លឹងម្រាមដៃខ្លួនដែលកំពុងប្រឹងក្ដាប់យ៉ាងណែនទប់ស្កាត់ការរំជួលចិត្ត គឺម្រាមដៃនេះ ដែលបានលើកកាំបិតចាក់រាមនរិន្ទកាលពីក្នុងព្រៃ។

រូបរាងគេដែលក្រឡាស់មកពាំងគ្រាប់សំណជំនួសនាង បានលេចឆ្លោឡើងមកក្នុងអារម្មណ៍ម្ដងហើយម្ដងទៀត សំណួរមួយចោទសួរក្នុងគំនិតនារីរូបល្អក្នុងពេលទន្ទឹមគ្នានោះ ថាបើរាមនរិន្ទដាច់ចិត្តប្រគល់នាងទៅឲ្យបុរសពុកចង្កាមែន តើគេចំណាយខ្លួនប្ដូរជីវិតមករងគ្រាប់សំណជំនួសនាងធ្វើអ្វី ?...

នាងងើបមុខសម្លឹងគ្រែដំណេកដែលនៅចង្អ្រឹងស្ងាត់ស្ងៀមកណ្ដាលបន្ទប់ មិនដែលមានពេលណាមួយដែលគេមិនប្រគល់មកឲ្យនាងនូវអនុស្សាវរីយ៍ផ្អែមល្ហែមគួរឲ្យចងចាំនោះទេ។ ថ្វីត្បិតថាគេប្រកាន់ចរិតដាច់ណាត់ទៅតាមអំណាចដែលគេមាន គេមិនសូវចេះនិយាយពាក្យផ្អែមល្ហែម មិនសូវមានពេលវេលាច្រើនផ្ដល់ឲ្យនាងដូចដែលមនុស្សស្រីនានាតែងត្រូវការ តែគេរមែងតែងធ្វើល្អចំពោះនាងនៅរាល់ពេលដែលនាងនៅជិតគេ គេរមែងខំប្រឹងបំពេញនូវសំណូមពររបស់នាងទោះជាពេលខ្លះសំណូមពរទាំងនោះឆ្កួតៗ និងល្ងង់ខ្លៅក៏ដោយ។

ពាក្យសន្ទនានានានៅលើទន្លេម៉េមបឺរ៉ាម៉ូកាលពីពេលថ្មីៗ លេចភ្លែតក្នុងការចងចាំរបស់នារី

"ម៉េចក៏លោកនិយាយរឿងអស់នេះប្រាប់ខ្ញុំ? អត់ខ្លាចខ្ញុំធ្វើឲ្យបែកការណ៍ទេ?"

"មនុស្សនៅជាមួយគ្នា ត្រូវទុកចិត្តគ្នា! មែនអត់? "សំឡេង និងស្នាមញញឹមដ៏គួរឲ្យកក់ក្ដៅរបស់គេវិលត្រឡប់មកវិញ។ ប៉ុន្តែកេតឪម៉ានឹកឃើញហើយមិនមែនសប្បាយចិត្តទេ នាងទៅជាស្រក់ទឹកភ្នែកតក់ៗ។ យប់មិញនេះទៀត បន្ទាប់ពីស្ដាប់ឮនាងនិទានរឿងផ្លែប៉ោមបីចប់កាលណា គេនិយាយ

មកកាន់នាងដោយបន្ទោសបុរសអ្នកជំនួញដែលមានភរិយាឈឺនោះថា "ហ្នឹងហើយ ដែលគេថាចេះតែស្រលាញ់ តែមិនយល់ចិត្ត! មនុស្សស្រលាញ់គ្នាតែមិនចេះទុកចិត្តគ្នា!"។

ជាមួយនោះរូបរាងគេដែលប្រថុយនឹងគ្រោះថ្នាក់ រត់បកក្រោយទៅរកអ្វីម្យ៉ាងមកជួយនាងនៅគ្រាដែលនាងជាប់គាំងនៅក្នុងគំនរជញ្ជាំងបាក់ឯសណ្ឋាគារ Winter Jayapura ក៏លេចឡើងក្នុងអារម្មណ៍នាងដូចនៅថ្មីៗដែរ។ ការចងចាំទាំងនោះហាក់ចង់បន្ទោសឲ្យនាងហួសចិត្តនឹងខ្លួនឯងថា ហេតុអ្វីក៏មុននេះ នាងដាច់ចិត្តលើកកាំបិតចាក់គេទៅកើត?។

ស្នូរទ្វាររបើកខ្ទាក ដាស់ចិត្តមាណវីឲ្យស្វាងចេញពីភាពច្របូកច្របល់ និងរវើរវាយដោយទុក្ខសោក។ ឪម៉ាស្ទុះក្រោកទាំងញាប់ញ័រ។ នុះន៎ បុរសជំនិតរបស់រាមនរិន្ទ គឺអង្គរក្សរឿន កំពុងឈរទ្រឹងនៅមាត់ទ្វារបន្ទប់ទាំងមុខខ្មៅប៉ែរ។ ពីក្រោយខ្នងកងការពារមួយក្រុមប្រកបដោយទឹកមុខស្លូតដូចគ្នា។

ការបង្ហាញខ្លួនហាក់ដូចជាប្រថុចញ៉ុចពេកនេះ បានធ្វើឲ្យកេតឪម៉ាភ្ញាក់ផ្អើល តែទឹកមុខពួកគេដែលបញ្ចេញច្បាស់ក្រឡែត នូវភាពអស់សង្ឃឹមដូចកំពុងត្រូវប្រឈមមុខចំពោះហេតុការណ៍អកុសលអ្វីមួយនេះ រឹងរឹតតែញ៉ាំងឲ្យនារីធ្លាក់សន្សឹមៗចូលទៅក្នុងអន្លង់នៃសេចក្ដីតក់ស្លុត ។

នាងហើបមាត់សួរយ៉ាងរហ័ស ៖

- រឿន! ឯណាលោកប្រុស? លោកប្រុសរាមយ៉ាងម៉េចហើយ ?

មិនចាំឲ្យពួកគេឆ្លើយទាន់ទេ ធីតាស្ទុះរឹងទៅកាន់បន្ទប់រាមនរិន្ទដែលនៅក្បែរនោះ ហើយពួកអ្នកការពារស្រងូតស្រងាត់ទាំងឡាយក៏មិនបានឃាត់នាងទៀតដែរ។

មកដល់មាត់ទ្វារបន្ទប់ នាងឃើញពេទ្យជនជាតិឥណ្ឌូណេស៊ីពីរនាក់កំពុងចាកចេញដោយអាការៈប្រញាប់ប្រញាល់ ។

នាងបង្ហាញម៉ូដចាប់តក់ស្លុត។ អារម្មណ៍អាក្រក់ៗផុសឆ្លោមកសង្កត់សង្កិនរាងកាយតរុណី ឲ្យឈានជើងបោះជំហានចូលបន្ទប់រាមនរិន្ទមិនចង់រួច។ នាងក្ដាប់ដៃយ៉ាងណែន ដើម្បីតាំងអារម្មណ៍ឲ្យនឹងន រួចទើបសម្រេចចិត្តលើកដៃបម្រុងរុញទ្វារចូល រំពេចនោះសំឡេងអង្គរក្សរឿនលាន់មកហាក់ក្រៀមក្រោះពីក្រោយខ្នង ៖

- លោកប្រុសមិនបានយល់ព្រមឲ្យនាងទៅតាមលក្ខខណ្ឌរបស់តាអូណ៍រទេ!...

សូរស័ព្ទមួយឃ្លានេះ ឌីម៉ាធ្លាប់ឮរួចហើយកាលក្នុងព្រៃ និងកាលនៅលើរថយន្តដែលគេជូននាងត្រឡប់មកទីនេះវិញ ប៉ុន្តែទាំងពីរលើកនោះពួកគេសម្ដែងអាកប្បកិរិយាហាក់ខឹងសម្បារនាងណាស់ ម្ដេចក៏លើកនេះនាងបែរជាទទួលអារម្មណ៍ថាសម្ដីរបស់មនុស្សជំនិតរាមនរិន្ទម្នាក់នេះពោលមកកាន់នាង មានភាពគួរសមទន់ភ្លន់ជាងមុន ប៉ុន្តែក្រៀមក្រំចម្លែក?។

នាងបែរក្រោយសម្លឹងម្ចាស់សំឡេង ក៏ឃើញអង្គរក្សរឿន និងកូនចៅនៅឈរពីមុខបន្ទប់នាងនៅឡើយ ហើយសម្លឹងមកនាងព្រមៗគ្នា។ ក្រសែភ្នែកពួកគេដែលបង្ហាញថាកំពុងមានទុក្ខកង្វល់អ្វីមួយបង្កប់ដោយអាថ៌កំបាំងនោះ បានធ្វើឲ្យតរុណីឌីម៉ាលែងរវល់ពីអ្វីទាំងអស់ ហើយងាកមករកបន្ទប់រាមនរិន្ទសាជាថ្មី រួចលើកដៃរុញទ្វារចូលឥតបង្អង់...។

ទ្វាររបើកតាមទំហំចិត្តជ្រួលច្របល់របស់អ្នកបើក។ កណ្ដាលបន្ទប់ធំទូលាយ និងត្រជាក់ស្រឹប ឌីម៉ានៅទ្រឹងសម្លឹងទៅរាងកាយអ្នកប្រុសអភិជន ដែលបិទភ្នែកជិតឈឹងលើបង្អែកគ្រែឈើ។

នាងឈានចូលទៅរកគេយឺតៗ កណ្ដាលភាពស្ងាត់ជ្រងំ និងក្រៀមក្រំរបស់ផ្ទៃបន្ទប់ ..។

តរុណីរូបល្អចូលមកចំពោះមុខគេហើយ គេនៅតែបន្តគេងផ្អែកខ្នងបិទភ្នែកដោយស្ងៀមស្ងាត់។ អាវគេត្រូវដោះចេញបាត់ពីពេលណាក៏មិនដឹង ជំនួសមកវិញដោយបង់រុំរបួស ដែលព័ទ្ធពីដើមទ្រូងនៅខាងក្រោយខ្នង។

នាងក្រមុំមើលមុខគេមិនដកភ្នែក។ នាងសម្គាល់ឃើញសញ្ញាឈឺចាប់ និងបាត់បង់ថាមពល បានបង្ហាញចេញពីផ្ទៃមុខដែលធ្លាប់តែស្រស់សង្ហា និងមានអំណាច។ បបូរមាត់ដែលតែងផ្ដល់មកឲ្យនាងនូវស្នាមញញឹមគួរឲ្យកក់ក្ដៅ ពេលនេះខ្មៅរោលហាក់គ្មានជីវិត។

កល្យាណីរូបល្អជ្រួញចិញ្ចើមទៅតាមការសង្វេគចិត្ត នាងក៏មិនដឹងដែរថា អង្គរក្សរបស់រាមនរិន្ទទាញទ្វារបន្ទប់បិទពីខាងក្រៅឲ្យជាស្រេច។

ស្រីស្រស់ដាក់បង្គុយយឺតៗក្បែរគ្រែ ឯភ្នែកក៏សម្លឹងរាមនរិន្ទឥតដាក់។ សន្សឹមៗ នាងលូកដៃទៅក្រសោបម្រាមទាំងប្រាំនៃដៃស្ដាំកំលោះអភិជន រួចលើកមកផ្ទប់នឹងផែនទ្រូង។

ដៃគេត្រជាក់ស្រិប តែទន់ល្មើយ។ គឺដៃនេះហើយ ដែលតែងក្រសោបចង្កេះនាងដោយកាយវិការស្រឡាញ់ថ្នាក់ថ្នម ហើយក៏ដៃនេះដែរដែលពេលមួយបានលើកម្រាមទាំងដប់របស់នាងមកថើប កាលណោះគេបាននិយាយពាក្យសុំទោស ដែលកម្រអ្នកណាបានឮចេញពីមាត់កូនប្រុសអ្នកតំណាងរាស្ត្រ។

ទឹកភ្នែកនាងស្រក់មកលើខ្នងដៃខ្លួនឯង ទន្ទឹមពេលសម្តីគេកាលពីយប់មិញរំលឹកមកវិញក្នុងសោតា ៖

"រស់នៅជាមួយរាមនរិទ្ធ វេទនាណាស់ទៅកេតឌីម៉ា?"

តរុណីលើកប្រអប់ដៃនរិទ្ធពីផែនទ្រូងមកផ្ទឹបក្បែរថ្ពាល់។ នាងកំពុងស្រមៃទៅដល់សេចក្តីសុខ និងភាពរំភើបចិត្តកាលពីគ្រាថ្មីៗដែលប្រុសម្នាក់នេះធ្លាប់បានផ្តល់មកឲ្យខ្លួន ហើយនាងដឹងថា នាងនៅមិនបានឆ្លើយ មិនបានប្រាប់គេឲ្យដឹងឡើយ នូវការពិតមួយដែលថា "រស់នៅជាមួយគេមិនប្រាកដថាគ្មានសេចក្តីសុខនោះទេ" ថ្វីត្បិតវាមាននូវទុក្ខព្រួយរហូតមក ប៉ុន្តែក៏បានបង្កប់មកជាមួយនូវសេចក្តីសុខសម្ងាត់គួរឲ្យចងចាំដែរ ។

ជាមួយភាពសោកសៅរំជួលចិត្ត ឌីម៉ាឥតហើបមាត់មួយម៉ាត់ តែទឹកភ្នែកបានរមៀលធ្លាក់មកដោយស្ងាត់ស្ងៀមក្នុងពេលតំណាលគ្នា...។

ស្រស់ស្រីឈ្ងោកមុខ បណ្តោយឲ្យទឹកភ្នែកស្រក់យ៉ាងជោគជាំតាមចិត្ត លុះមពេលដែលត្រចៀកស្តាប់ឮសំឡេងស្រាលៗមួយបន្លឺមកកាន់ខ្លួន ៖

- យំធ្វើអ្វី? ឌីម៉ា?

អ្នកគ្រូវ័យក្មេង ងើបមុខយ៉ាងរហ័ស។ នាងប្រទះឃើញផ្ទៃមុខស្លេកស្លាំងនៃកំលោះត្រកូលខ្ពស់ប្រឹងញញឹមដោយក្រៀមក្រំ ហើយកែវភ្នែកទាំងគូ ក៏កំពុងបើកសម្លឹងមកនាងក្នុងពេលជាមួយគ្នា។...

ឌីម៉ាទប់ចិត្តលែងបាន ទឹកភ្នែកដែលមុននេះហូរមកដោយស្ងៀមស្ងាត់នោះ ពេលនេះបានអមមកជាមួយនូវសូរស័ព្ទសោកសង្រេងយ៉ាងកម្សត់ បង្ហាញនូវការស្តាយក្រោយឥតពណ៌នានៃនារីម្នាក់ដែលបានជាធ្វើខុសចំពោះមនុស្សខ្លួនស្រឡាញ់។

នាងក្រសោបដៃគេណែនជាងមុនទាំងយំសស្រាក់ និងសម្លឹងគេមិនដកភ្នែក។ ពន្លឺភ្នែកគេបង្ហាញស្រេចហើយថា គេនៅតែអភ័យទោសឲ្យនាង ដូចរឿងឆ្គួតៗទាំងឡាយដែលនាងសាងឡើងកាលពីមុនរហូតមកដែរ។ នាងលើកដៃគេមកផ្ទឹបជាប់នឹងថ្ពាល់ដែលសើមជោកទៅដោយទឹកភ្នែក។

រាមនរិទ្ធញញឹមហាក់មិនរវល់នឹងមុខរបួសរបស់ខ្លួន ប្រហែលដោយសារនេះជាទិដ្ឋភាពមួយគេត្រូវចងចាំទុក ព្រោះកន្លងមកក្រៅពីមិនហ៊ានបម្រះប្រកែកប្រណាំងនឹងគេ តែឌីម៉ាក៏មិនដែលបញ្ចេញកាយវិការយកចិត្តទុកដាក់ចំពោះគេដូចពេលនេះឡើយ។

គេសម្លឹងមុខនាងដែលយំសស្រាក់ បបូរមាត់ក្រហមស្រស់ដូចសេកសោមកំពុងញ័រទទ្រើកនោះ គឺជាសញ្ញាបញ្ជាក់ច្បាស់លាស់ហើយ ថានាងកំពុងឈឺចាប់ដោយពិតៗឥតក្លែងបន្លំទេ។ គេដកដៃចេញយឺតៗពីប្រអប់ដៃនាង តែមាត់ពោលស្រាលៗ ៖

-ហើយអ្នកណាប្រាប់ថា បងឲ្យឌីម៉ាទៅនៅជាមួយពួកនោះ?

កេតឌីម៉ានៅទ្រឹងក្នុងពេលដែលកំលោះសង្ហាលើកដៃអង្អែលក្បាលនាងថើៗ។ ព្រោះក្តីរំភើប នាងក្រោកមកស្រវាលាដៃឱបអ្នកកំលោះអភិជនជាប់ ហើយផ្ទឹបក្បាលក្បែរទ្រូងគេដោយយំអណ្តឹតអណ្តក។

- សូមទោស !

នេះជាពាក្យពីរម៉ាត់គត់ ដែលនាងទើបនឹងបន្លឺចេញមក បន្ទាប់ពីនាងបានឈានចូលមកដល់បរិវេណបន្ទប់នេះអស់ជាច្រើននាទីមកហើយ។ រាមនរិន្ទលើកម្រាមដៃច្បូតសរសៃសក់វែងអន្លាយដែលទ្រោបទៅជិតទ្រូងបង្អើយ ពិដោរក្រអូបប្រហើរនៃកេសាធីតាម្ចាស់ចិត្តធ្វើឲ្យអ្នកកំលោះភ្លេចបាត់អស់នូវការឈឺចាប់នៃមុខរបួសទាំងប៉ុន្មាន។ គេបន្លឺស្រាលៗក្នុងពេលដែលនាងក្រមុំរូបល្អយំខ្សឹកខ្សួលដោយវិប្បដិសារី ៖

- ជិតបានចេញពីភូមិនេះហើយ!

ឌីម៉ាងើបក្បាលចេញពីរាងកាយគេ នាងសម្លឹងអ្នកកំលោះទាំងភ្នែកព្រិលរកាំ។ នាងប្រទះឃើញរាមនរិន្ទសម្លឹងមកខ្លួនដោយក្រសែភ្នែកអណ្តែតអណ្តូង មិនសក្តិសមជារាមនរិន្ទអភិជនមានអំណាចដែលដែលនាងធ្លាប់ស្គាល់ពីគ្រាដំបូងនោះទៀតឡើយ។

អារម្មណ៍សម្ងាត់នៃមនុស្សដែលមានចរន្តផ្លូវចិត្តវេញត្របាញ់រកគ្នា បានដាស់ឲ្យធីតាដឹងប្រាកដក្នុងពេលនេះថា គេមិនបានទុកនាងជាកូនបំណុលដូចដែលនាងធ្លាប់ស្មានរហូតនោះទេ។ ហើយគេក៏មិនមែនប្រភេទយកមនុស្សស្រីសម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់ការងារខ្លួនដូចពាណិជ្ជករដែកថែបឈ្មោះ Kenដ៏ថោកទាបនោះដែរ។

ទឹកមុខគេ ពន្លឺភ្នែកគេ ពាក្យសម្តីគេ ជាសក្ខីភាពជាក់ស្តែងណាស់ថា គេកំពុងត្រូវការពីនាងនូវការស្រលាញ់ផ្លូវចិត្ត ខុសពីការស្រលាញ់ផ្លូវកាយដែលគេធ្លាប់ទទួលពីនាងក្នុងគ្រាកន្លងមក។

រយៈកន្លងមក រាប់ចាប់តាំងពីថ្ងៃដែលជីវិតនាងត្រូវជួបជំពប់ជាមួយអភិជនកំលោះរូបនេះហើយចុងក្រោយនាងត្រូវរងរបួសផ្លូវចិត្តយ៉ាងដំណំដោយស្នេហាបោកប្រាស់របស់នាយKenទៀត នាងគិត

ជានិច្ចថា អ្នកមានមិនដែលមានបេះដូង ដែលផ្ទុកដោយពណ៌ភក្ដីភាពទេ ពួកគេមានតែបេះដូង ដែលផ្ទុកដោយការមើលងាយប្រមាថមនុស្សដូចគ្នាទៅតាមអំណាចទឹកប្រាក់ដែលគេមាន។ ហើយ បើគាប់ជួនជាគេមានឱកាស និងមានប្រាជ្ញាផង គេនឹងឆ្លៀតកេងប្រវ័ញ្ចបោកបញ្ឆោតមនុស្សដែលខំ ស្មោះស្ម័គ្រនឹងគេ។

រាមនរិន្ទដ៏ស្រស់សង្ហា ប្រាជ្ញាឈ្លាសវៃ ចិត្តបើកទូលាយ និងមានទស្សនៈជីវិតវែងឆ្ងាយ តើមានខ្វះ ចំណុចណាទៀតដែលអាចឃាត់ឌីម៉ាមិនឲ្យរំភើបចិត្តនោះ តែនាងមិនដែលនិយាយ មិនដែលហ៊ាន គិត ព្រោះស្នេហាខុសវណ្ណៈបានផ្ដល់មេរៀនជូរចត់ថ្មីៗមិនទាន់បាត់ស្នាមផង។

ការស្មានខុសបានអូសបន្លាយពេលឲ្យកន្លងទៅ ដោយគ្មានប្រយោជន៍ ហើយបណ្ដាលឲ្យប្រអប់ បេះដូងពីរដែលមានចេតនារត់រកគ្នានេះ ក្លាយទៅជាមិនយល់ចិត្តបែកចេញពីគ្នា ទោះបីរាងកាយ នៅនែបនិត្យក្បែរគ្នារាល់ថ្ងៃក្ដី។

តែថ្ងៃនេះដឹងច្បាស់ហើយថាគេក៏ស្រលាញ់នាង ដូចដែលនាងលង់ចិត្តទៅលើគេ តែនាងនៅតែរក ពាក្យអ្វីនិយាយទៅរកគេវិញមិនបាន បានត្រឹមឈ្ងោកមុខចំពោះពន្លឺភ្នែកទេវបុត្រកំពូលស្នេហ៍ ... ។...

រាមនរិន្ទក្អកតិចៗកាត់ផ្ដាច់អារម្មណ៍រវើរវាយរបស់ឌីម៉ា។ នាងងើបមុខសម្លឹងគេវិញយ៉ាងរហ័ស។ ឃើញអ្នកកំលោះកម្រើកខ្លួនតិចៗ តែទឹកមុខគេជ្រួញជ្រីវដោយភាពឈឺចាប់ជំនួសសំឡេងថ្ងូរ... នាងពោលទៅរកគេភ្លាម...

-លោកប្រុសរាម? ឈឺណាស់មែនទេ? ខ្ញុំទៅតាមពេទ្យណា៎?...

នាងស្រវាក្រោកតែរាមនរិន្ទចាប់ដៃវិញហើយពោលតិចៗ ៖

- រកលេសទៅចោលទៀតហើយ?

ឌីម៉ាហួសចិត្ត នាងអស់ពីយំទៅជាចង់អស់សំណើច។ មនុស្សប្រុសពេលមាយាក៏មិនខុសអីពីក្មេង តូចដែរ។ នាងច្រត់ដៃក្រោកតែគេចាប់ដៃនាងជាប់។ តរុណីញញឹមលុបបំបាត់ភាពក្រៀមស្រពោន លើផ្ទៃមុខ....ទាំងបន្លឺទៅកាន់គេ ៖

-ទៅយកភួយទេតើ!...

នាងដកដៃចេញពីគេថ្នមៗ រួចងើបដើរទៅយកភួយពីគ្រែមកដណ្ដប់ឲ្យគេ ទាំងផ្ទៃបន្ទប់កំពុងត្រជាក់ស្រិបដោយសន្សើមរាត្រី។

ស្រស់ស្រីឱនដណ្ដប់ភួយឲ្យកំលោះម្ចាស់ចិត្ត ពេញដោយការអាណិតស្រឡាញ់ដូចទុកឱកាសឲ្យគេពោលស្រាលៗមកកាន់នាង ៖

- បងស្រលាញ់អូន ឌីម៉ា!

រាងកាយក្រមុំបង្ហាញម៉ូត នៅទ្រឹងស្ងៀមហាក់គាំងចលនានិម្មិត តែព្រះពាក្យប៉ុន្មានម៉ាត់ចុងក្រោយនេះ។ កែវភ្នែករាមនរិន្ទទាំងគូ ដែលសម្លឹងចំមកភ្នែកមាណវីយើងកំពុងស្រូបទាញយកអស់នូវព្រលឹងនាង ឲ្យគិតអ្វីលែងឃើញក្រៅពីសម្លឹងតបទៅគេដោយភ្លឹកភ្លាំង។

ពិតណាស់ហើយថានាងបានដឹងពីអារម្មណ៍ល្អដែលរាមនរិន្ទតែងមានចំពោះនាងរហូតមក។ សេចក្ដីសុខទាំងប៉ុន្មានដែលគេតែងព្យាយាមផ្ដល់មកឲ្យនាងកាលគ្រានៅក្បែរគ្នា ក៏បានធ្វើឲ្យនាងសង្ស័យខ្លះៗដែរថានាងអាចមានសារៈសំខាន់មួយចំណែកណានោះនៅក្នុងចិត្តគេ។

រហូតដល់គេសម្រុកចូលព្រៃរកនាងទាំងយប់ ហើយរងគ្រាប់កាំភ្លើងជំនួសនាងទៀត រឹតតែបង្ហាញច្បាស់ឡើងថាគេគិតយ៉ាងណាចំពោះនាងនោះ។ ការសម្រេចចិត្តបោះបង់ឥន្ទប្បដិមាហើយជ្រើសយកនាងបានធ្វើឲ្យនាងរំភើបចិត្ត តែអ្វីៗទាំងអស់នោះ សុទ្ធតែគ្មានតម្លៃស្មើនឹងពាក្យមួយឃ្លាចុងក្រោយនេះបានទេ ។

ភាគទី៣៧

នៅចំពោះមុខបុរសដែលខ្លួនស្រលាញ់ នារីណាក៏ចង់ព្រះពាក្យ "ស្រលាញ់" ចេញពីមាត់គេដោយពិតៗដែរ ឯពាក្យ "បងស្រលាញ់អូន" ដែលកំលោះអភិជនដាច់ចិត្តបង្ហើបចេញនៅយប់នេះអាចយូរបន្តិចហើយក្ដីស្នេហ៍ដែលដុះពន្លកក្នុងចិត្តគេតែបែរជាឆាប់រហ័សសម្រាប់អ្នកគ្រូបង្ហាញម៉ូត រកតែនាងស្មានមិនដល់សោះតែម្ដង ។

ឌីម៉ាឈ្ងោកមុខ ថយចេញមកអង្គុយក្បែរជើងកៅអីវិញដោយស្ងៀមស្ងាត់ តែចិត្តនាងកំពុងច្របូកច្របល់រកពណ៌នាមិនត្រូវ។ សំឡេងកំលោះរូបល្អបន្តមកស្រាលៗបន្ថែម ៖

- ចុះអូនវិញ ?..

ពាក្យបន្ថែមដ៏ខ្លីបីម៉ាត់នេះ បានធ្វើឲ្យឌីម៉ាដឹងថានេះគឺជាហេតុការណ៍ពិតមិនមែនសុបិនទេ ព្រោះគេកំពុងសម្លឹងរកនាងដោយទឹកមុខស្លូត។

ចុះអូនវិញ? បានន័យថានាងស្រលាញ់គេវិញដែរឬអត់? នាងក្រមុំងាកមុខចេញសាជាថ្មី មិនមែននាងមានចិត្តចង់ធ្វើឲ្យគេខ្នក់ចិត្តទេ តែតាមពិតគឺនាងមិនដឹងថាគួរឆ្លើយប្រាប់ទៅគេវិញយ៉ាងម៉េច។

នាងដណ្ដឹងសួរស្ងាត់ៗក្នុងចិត្ត៖

"រាមនរិន្ទមិនដឹងមែន ឬក៏គេធ្វើពើទេ? តើមាននារីណាខ្លះដែលមិនបាក់ចិត្តស្រលាញ់ចំពោះមនុស្សដែលដណ្ដើមបានរាងកាយខ្លួន ហើយផ្ដល់មកនូវអនុស្សាវរីយ៍ផ្អែមល្ហែមរហូតមកនោះ? បើមិនស្រលាញ់ សុខចិត្តឲ្យស្រក់ទឹកភ្នែកអស់មួយតំណក់ធ្វើអី? បើមិនស្រលាញ់ ខ្ញុំតាមលោកមកផ្សងព្រេងឆ្ងាយយ៉ាងនេះដែរ?"

-ឌីម៉ា!

បុរសហៅនាងម្ដងទៀត ជាសញ្ញាចង់ឲ្យនាងឆ្លើយសំនួរគេ។ ដូច្នេះនាងមិនដឹងធ្វើម៉េច ក៏រំកិលខិតចូលទៅជិតគេសាជាថ្មី ហើយលាវង្វង់ដៃឱបរាងកាយកំលោះម្ចាស់ចិត្តម្ដងទៀតដោយចាត់ថា នេះគឺជាចម្លើយយ៉ាងសមល្មម ជំនួសឲ្យសម្ដីដែលស្ដីមិនរួចសោះនោះ។

កំលោះអភិជនហួសចិត្ត ព្រោះក្នុងឆាកជីវិតខ្លួនដែលបានជួបនារីជាច្រើនរួចមកហើយ ដូចជានឹកមិនឃើញថា មានស្ត្រីណាដែលមានចរិតស្ងៀមស្ងាត់ និងចម្លែកដល់ថ្នាក់នេះសោះ។ គេសួរខ្លួនឯងក្នុងចិត្ត៖

"ស្រីនេះឆ្កួតដល់ម្លឹង បានជាឯងដកចិត្តពីនាងមិនបានមែនទេ រាមនរិន្ទ?"

ស្រីស្អាតសួរសំនួរបន្លប់មនោសញ្ចេតនារបស់គេ៖

-លោកលែងតាមរកឥន្ទប្បដិមាហើយ!

គេគ្រវីក្បាលតិចៗ៖

-អត់ទេ! នោះជាពាក្យសន្យារបស់លោកពុកចំពោះដូនតាជំនាន់មុន ហើយពេលនេះវាក្លាយជាពាក្យសន្យារបស់បងទៀត! បងមិនទុកបន្ទុកនេះតរហូតដល់កូនយើងទេ!

"កូន"? ស្រីស្អាតទទួលអារម្មណ៍ថានាងស្ដាប់ខុស។ បុរសដូចរាមនរិន្ទនេះឬដែលនិយាយពាក្យ "កូន" ជាមួយស្រីជំពាក់បំណុលដូចនាង?

បុរសដែលណាត់នាងទៅជួបនៅអាម៉ាន់ដារីដើម្បីតែសម្ដែងឫទ្ធិបង្អួតអ្នកផង ហើយក៏ជាបុរសដែលមិនធ្លាប់វិលមករកនាងជាលើកទី២ បន្ទាប់ពីបានរាត្រីទីមួយហើយនោះ ទីបំផុតគេប្រើពាក្យនេះជាមួយនាង?

ពេលនាងកំពុងនៅនឹងថ្កល់ គេលើកដៃអង្អែលក្បាលនារីម្ចាស់ស្នេហ៍ថ្នមៗ ទាំងស្រលាញ់ពេញបេះដូង។ គេនិយាយបន្ត៖

-តែបងមិនយកអូនទៅដូរយករបស់នោះទេ! តានោះឆ្កួតហើយ ដែលស្រមៃចង់យកអូនចេញពីបង!

នារីយល់ហើយពីអ្វីដែលគេកំពុងនិយាយ នាងងើបមុខសម្លឹងគេលែងអៀនប្រៀន ឬខ្លាចចិត្តដោយសារត្រូវលង់ក្នុងមន្តស្នេហ៍គេពេញទំហឹង។ នាងញញឹមហើយធ្មេចភ្នែកក្នុងរង្វង់ដៃបុរសរងរបួសស្របពេលព្រះចន្ទយាងចាកចោលនភាល័យ ជាសញ្ញាថារាត្រីកាលបានរំលងផុតអាធ្រាត្រទៀតទៅហើយ ។

តរុណីរូបល្អ និងកំលោះអភិជនលង់លក់ ក្រោមការបបោសអង្អែលនៃសន្សើមរាត្រីព្រមទាំងសព្ទសត្វរាត្រីចរលាន់មកល្វើយៗ។

ស្នូរគោះទ្វារលាន់ឡើងជាច្រើនដង លុបបំបាត់ភាពស្ងប់ស្ងាត់នៃផ្ទៃបន្ទប់។ នរិន្ទជ្រួញចិញ្ចើមស្វាងចេញពីដំណេក គេបើកភ្នែកព្រឹមៗ ល្មមពេលតរុណីឌីម៉ាងើបក្បាលចេញពីលង្វែកទ្រូងអ្នក។

នាងក្រមុំច្រត់ដៃក្រោកឈរ ស្របពេលមនុស្សមួយក្រុមរុញទ្វារចូលមកដល់។ អ្នកទាំងនោះគ្មានអ្នកណាក្រៅពីមនុស្សជំនិតក្រោមបង្គាប់រាមនរិន្ទ ដែលមុននេះប៉ុន្មានម៉ោង ឌីម៉ាបានជួបពីខាងក្រៅបន្ទប់ទេ។ ប៉ុន្តែទឹកមុខ និងសកម្មភាពពួកគេដែលសម្រុកចូលហាក់គ្មានសុជីវធម៌ ក្នុងពេលនេះបានជំរុញឲ្យនារីបង្ហាញម៉ូដនឹកពិភាល់ក្នុងចិត្តថា អ្នកទាំងនេះពិតជាបានជួបហេតុការណ៍អ្វីមិនល្អហើយ។

មិនទាន់មានអ្នកណាក្នុងចំណោមអ្នកទាំងពីរ ពោលសួរទៅមនុស្សក្រោមបង្គាប់យ៉ាងណាផង ស្រាប់តែនាយជំនិតរឿន ពោលយ៉ាងបន្ទាន់មកកាន់រាមនរិន្ទ៖

- អ្នកប្រុស...ពួក....ពួកកុលសម្ព័ន្ធ....វ៉ា

ឃើញគេរលះរលាំងហត់គយូសក៏នៅនិយាយមិនចប់សំឡេង រាមនរិន្ទបន្លឺមួយៗកាត់សម្ដីជនក្រោមបង្គាប់ ៖

- រឿន !... និយាយតាមសម្រួលទៅ ...!...

អង្គរក្សខ្ពស់ស្រាវពោលដោយទឹកមុខព្រួយបារម្ភ ៖

-គ្នាយើងនៅខាងក្រៅប្រាប់មកថា ពួកកុលសម្ព័ន្ធមកជុំគ្នានៅក្រោមហើយ... ដូចយើងស្មានទុកអញ្ចឹង!... ច្បាស់ជាមានរឿងហើយ !...

ឱម៉ាធ្លាក់ថ្លើមក្តុក... នាងរវេភ្នែកសញ្ជឹងគិតទាំងអារម្មណ៍តក្កមា... បានន័យថាកាលដែលនរិន្ទមិនព្រមប្រគល់នាងឲ្យម្ចាស់កោះ ក៏មិនប្រាកដថានាងអាចបានសុខដែរ ព្រោះទីនេះជាទឹកដីរបស់គេ។ នាងស្រាប់តែនឹកឃើញឡើងវិញពីទឹកមុខកូនចៅគេដែលខ្មៅអែគ្រប់គ្នា ពេលដែលនាងជួបនៅឯក្រៅបន្ទប់ តាមពិតពួកគេបានស្មានដឹងទៅហើយថាបុរសពុកចង្កានោះមិនមែនព្រមលើកលែងឲ្យរាមនរិន្ទងាយៗទេ ឥឡូវនេះហេតុការណ៍អកុសលពិតជានឹងកើតឡើងយ៉ាងប្រាកដហើយ ។

នាងក្រមុំងាកទៅរករាមនរិន្ទទាំងរន្ធត់ចិត្ត ប៉ុន្តែនាងឃើញគេរក្សាភាពស្មើធេងលើផ្ទៃមុខ គ្មានសញ្ញាថាតក់ស្លុត ឬភិតភ័យឡើយ។ ចំណែកនាងវិញធ្វើចិត្តដូចគេមិនបានឡើយ នាងងាកពោលទៅរកគេដោយសូរស័ព្ទរញ៊ីររញ៉ៃរ និងកាន់កំភួនដៃប្រុសស្នេហ៍ជាប់៖

- គេចង់ធ្វើអីយើង??...

រាមនរិន្ទដៀងភ្នែកមករកស្រស់ស្រី ដែលកំពុងបង្ហាញទឹកមុខភ័យបារម្ភក្បែរខ្លួនបង្អើយ... គេញញឹមស្ងួត រួចពោលទៅរកនាងទាំងមិនកម្រើកខ្លួន ៖

- គ្មានអ្នកណាធ្វើបាបអូនបានទេ!...

ឱម៉ាគ្រវីក្បាលទាំងច្របូកច្របល់ចិត្ត...

- តែ... លោកកំពុងមានរបួស!..គេអាចនឹងឆ្លៀតពេលនេះ ធ្វើបាបលោក!...ណ៎ា?...

បុរសសម្លឹងនាងដោយទឹកមុខញញឹម តាមពិតគឺគេកំពុងភ្ញាក់ផ្អើល និងគិតថានាងកំពុងព្រួយបារម្ភពីនាយអីដល់ថ្នាក់នេះ។ ទោះបីបុរសអភិជនរូបសង្ហារក្សាភាពនឹងនបាន នារីមិនបានធូរចិត្តបន្តិចទេ... នាងអន្ទះសា ហើយងាកមករកក្រុមមនុស្សដែលកំពុងមានវត្តមាននៅទីនេះ ៖

-បងរឿន! យើងមានមធ្យោបាយអីទេ? យើងមិនអាចនៅរង់ចាំឲ្យគេធ្វើបាបបានទេ!...

មនុស្សជំនិតឈ្មោះរឿន ដៀងភ្នែកទៅរកម្ចាស់ប្រុសរង់ចាំបញ្ជា។ រាមនរិន្ទងក់ក្បាលដាក់គេទាំងមាត់បន្លឺឡើង៖

-នាំឪម៉ាទៅមុនទៅ ...!...

ជនក្រោមបង្គាប់ឆ្លើយបាទយ៉ាងរហ័ស តបទៅនឹងបទបញ្ជានៃថៅហ្វាយប្រុស។... គេងាកមករកឪម៉ាទាំងពោលដោយប្រញាប់ ៖

- អញ្ជើញ !...

ឪម៉ាសម្លឹងមុខគេ រួចងាកមករកនរិន្ទ៖

- ឲ្យគេនាំខ្ញុំទៅណា ?...

រាមនរិន្ទ មិនទាន់ឆ្លើយតបថាយ៉ាងណាផង នាយរឿនឆ្លើយមុន៖

- ចេញពីកន្លែងនេះ! ពួកគេមកដល់ នាងអាចមានគ្រោះថ្នាក់! នាងជាគោលដៅដែលគេចង់បាន!

ឪម៉ាជ្រួញចិញ្ចើម តែអង្គរក្សរឿនតឿនបន្ត ៖

- ឆាប់ឡើងអ្នកនាងឪម៉ា?... យើងអស់ពេលហើយ !...

ស្រីស្រស់ងាកមករកនរិន្ទ ដែលកំពុងផ្អែកស្មៀមនឹងក្បាលគ្រែ... នាងវាចាទៅរកគេ ៖

- លោកប្រុសរាម!... យើងទៅទាំងអស់គ្នា ...!... ពួកយើងនឹងគ្រាលោកទៅ !...

នាងក្រមុំក្រោកឈ្ងោកគ្រារាងកាយបុរសរូបល្អ...តែគេបន្លឺឡើងមុននាងលូកដៃទៅដល់៖

- រឿន !... កុំនៅអែអង់ !... នាំនាងទៅភ្លាម !...

អង្គរក្សរឿនស៊ីញ៉ូភ្នែកឲ្យនាយBirdធ្វើឲ្យជនបង្កប់លូកដៃមកទាញឪម៉ា និងបង្ខំឲ្យចាកចេញពីបន្ទប់ទាំងត្រដាបត្រដួស។

ក្នុងមួយខណៈ ដែលតរុណីយើងកំពុងភ័ន្តភាំង នាងត្រូវគេអូសមកដល់មាត់ទ្វារបន្ទប់រួចទៅហើយ។គង់ដែលដើរតាមពីក្រោយនាយBird ដោយមានភារៈនាំឪម៉ាចាកចេញនោះ ទុចដំណើរងាកមករកថៅហ្វាយកំលោះដែលកំពុងផ្អែកស្មៀមលើបង្អែកគ្រែ។

ក្នុងក្រសែភ្នែកក្រៀមក្រំ នាយគង់និយាយដោយស្លូតស្ងប់ ៖

- អ្នកប្រុស !... សូមសំណាងល្អ !

គេងាកទៅរកអង្គរក្សរឿនដែលជាមេកើយ ហើយនិយាយដោយម៉ឺងម៉ាត់៖

- បងរឿន! ពួកខ្ញុំនៅកំពង់ផែបញ្ជោះទូកចាំ! បងត្រូវនាំអ្នកប្រុសទៅកុំខាន!

គេក្តាប់ដៃឌីម៉ាណែនជាងមុន រួចអូសនាងចេញទៅ។ ស្វាងចេញពីភាពភ័ន្តភាំង កល្យាណ កញ្ជ្រោលពីដៃនាយគង់... នាងងាកមករកអ្នកកំលោះម្ចាស់ចិត្ត... ល្មមពេលដែលក្រសែភ្នែកក្រៀមក្រំរបស់គេកំពុងសម្លឹងនាងមិនដាច់...។..

ទឹកភ្នែកស្រក់មកច្រោកដោយឥតព្រាងទុក... នាងស្រែកដោយទប់ចិត្តលែងបាន ៖

- អត់ទៅទេ !... បើទៅ... ត្រូវទៅទាំងអស់គ្នា !

តែម្តងនេះឌីម៉ាពិតជាខកចិត្តហើយ ព្រោះថាឈ្មោះគង់ គេស្តាប់បង្គាប់នរណាក្រៅពីរាមនរិន្ទទ្បើយ ...។ គេទាញរាងកាយតូចតន់ចាកចេញយ៉ាងរហ័ស ទោះបីនាងកញ្ជ្រោលអស់កម្លាំងកាយចិត្តហើយក្តី ...។

មកដល់មាត់ជណ្តើរ មិនដឹងជាគិតឃើញយ៉ាងម៉េចបានជាគង់ និងគ្នីគ្នាស្ទុះសំដៅទៅរានហាលនៃបន្ទប់ទទួលភ្ញៀវវិញ...។ ពួកគេនាំគ្នាសម្លឹងទៅជាន់ខាងក្រោម គឺចម្ការត្របែក...ដែលនៅទីនោះឌីម៉ាបានប្រទះឃើញរថយន្តជាច្រើនកំពុងបោលសម្រុកចូលមក។

ស្នូររថយន្តរំពង លប់បំបាត់ភាពស្ងាត់ជ្រងំនៃរាត្រីកាលនេះ ហាក់បីដូចជាដាស់ចិត្តឌីម៉ាឲ្យដឹងថា... គ្រោះថ្នាក់បានចូលមកដល់ហើយ។

នាយគង់ងាកមករកគ្នីគ្នាទាំងបញ្ជាប្រាប់៖

- ចុះតាមជណ្តើរខាងក្រោយវិញ ...!...

ឌីម៉ាត្រូវជននេះអូសវាងជណ្តើរមុខទៅកាន់ជណ្តើរថ្មើជើងឯក្រោយផ្ទះសំណាក់ នាងដឹងថា... ពួកគេចង់នាំនាងគេចចេញពីការមកដល់របស់ក្រុមកុលសម្ព័ន្ធ តែក្នុងស្ថានភាពដ៏ប្រថុចញ៉ុចនោះស្រស់ស្រីឈ្ងោកខាំដៃនាងគង់អស់ទំហឹង ទាល់តែគេស្រែកអូយព្រមទាំងលែងដៃដែលអូសនាងនោះផង។

បានដូចចិត្ត តរុណីយើងស្រវាលើកជាយសំពត់ ស្ទុះត្រឡប់ក្រោយមករកទីដែលម្ចាស់បេះដូងកំពុងមានវត្តមាន។ នាងសម្រុកចូលទៅរករាមនរិន្ទ ទាំងមិនបានគោះទ្វារឲ្យសញ្ញាមុនទ្បើយ... ក្នុងខណៈដែលឈ្មោះរឿន និងគ្នីគ្នាដែលនៅខាងក្នុងបើកភ្នែកគ្រលួង ឯនាយគង់ និងនាយBirdក៏ស្ទុះមកតាមនាងយ៉ាងរហ័សដែរ។

មកដល់ក្នុងបន្ទប់ នាងឃើញរាមនរិន្ទអង្គុយស្ងៀមលើគ្រែឈើដូចដើម...។ ចិញ្ចើមទាំងគូនៃកំលោះអភិជនជ្រួញបន្តិច ពេលឃើញវត្តមាននារីម្ចាស់ចិត្ត មិនចាំបាច់និយាយក៏យើងដឹងបានថាគេកំពុងងឿងឆ្ងល់ និងមិនសប្បាយចិត្តពេលឃើញឪម៉ា មិនទាន់ចេញផុត។

នាងក្រមុំស្ទុះចូលក្បែរគេ ទាំងពោលទៅរកគេយ៉ាងរហ័ស ៖

- ឲ្យខ្ញុំនៅទីនេះផង !...ណ៎ា !... ខ្ញុំមិនទៅទេ !...

រាមនរិន្ទមិនទាន់និយាយនៅឡើយ ... សំឡេងនាយរឿនលាន់ឡើងមុន ៖

- បើនាងនៅអែអង់ទៀត យឺតពេលហើយ!...

មនុស្សជំនិតរូបនេះស្ទុះមករកតរុណីសាជាថ្មី តែឪម៉ារហ័សចាប់ដៃរាមនរិន្ទជាប់... នាងពោលអង្វរគេទាំងរលីងរលោង ៖

- លោកប្រុសរាម !... កុំឲ្យគេនាំឪម៉ាទៅ ! ណ៎ា ! ?...

កូនប្រុសអ្នកនយោបាយដែលកំពុងធ្លាក់ក្នុងអន្ទាក់ដ៏គ្រោះថ្នាក់ ពោលទៅរកនាងទាំងសម្លឹងផ្ទៃមុខស្រស់ផូរផង់ ដែលកំពុងនៅក្បែរខ្លួនបង្កើយ ៖

- អត់ខ្លាចគេធ្វើបាបទេកេតឪម៉ាស្រីល្ងង់?

ស្រស់ស្រីតោងដៃប្រុសស្នេហ៍ ហាក់ដូចខ្លាចរបេះចេញពីគ្នា ៖

- តែគេក៏នឹងធ្វើបាបលោក! លោកមានរបួសហើយ...ស៊ូនឹងគេមិនបានទេ... ណាមួយនេះជាទឹកដីដែលគេកាន់កាប់ផង !...

រាមនរិន្ទហួសចិត្តនឹងអាកប្បកិរិយានារីម្ចាស់ចិត្តណាស់... ព្រោះរាល់ដងនាងមិនដែលនិយាយរកអ្នកឲ្យហួសពីមួយប្រយោគទេ... ស្រាប់តែពេលនេះម៉េចក៏នាងនិយាយចេញច្រើនម្ល៉េះ ?...

នរិន្ទញញឹម...ព្រោះកាយវិការទាំងអស់នេះវាបញ្ជាក់ស្រេចទៅហើយ...ថានាងក៏ស្រលាញ់អ្នក មិនខុសពីអ្នកស្រលាញ់នាងយ៉ាងលើសលប់នោះដែរ។ អ្នកកំលោះយើងពោលតិចៗ ទាំងសម្លឹងមុខនាងក្រមុំ ៖

- ស្រីឆ្កួត!... មិនខ្លាចពួកកុលសម្ព័ន្ធទេឬយ៉ាងម៉េច ?...

ភាពទ័លច្រកបញ្ចេញមកតាមរយៈពន្លឺភ្នែកទាំងគូ នារីបន្លឺទាំងគ្រវីក្បាល ៖

- ខ្ញុំមិនជឿថាគេហ៊ានធ្វើល្មើសច្បាប់ចំពោះភ្ញៀវទេ !...គេមិនអាចសម្លាប់យើងតាមចិត្តនឹកឃើញទេ!...

រាមនរិន្ទមិនទាន់ឆ្លើយតបនឹងតរុណីយ៉ាងណាផង សំឡេងមួយលាន់គ្រអៅមកពីមាត់ទ្វារបន្ទប់ ៖

- ត្រូវ !...គ្មានអ្នកណាដាច់ចិត្តសម្លាប់ស្រីស្អាតដូចនាងទេ!...

ក្នុងបរិយាកាសភ័យរន្ធត់ មាណវីងើបមុខយ៉ាងរហ័ស សម្លឹងម្ចាស់សំឡេង ដែលនាងជឿជាក់ថាធ្លាប់ស្គាល់ប្រាកដណាស់ ។

... សំរិបជើងមនុស្សច្រើននាក់ឈានចូលមកដល់... មានទាំងរូបរាងច្រឡើសបើសនៃនៃបុរសវ័យក្មេងមួយរូប ដែលឪម៉ាទើបតែត្រូវគេធ្វើឲ្យសៅហ្មងនៅឯចម្ការកាលពីម្សិលមិញ។ ហើយគេដដែលធ្លាប់បានប្រមាថនាងម្តងរួចមកហើយ នៅឯភោជនីយដ្ឋានកាលដែលនាងទើបនឹងទៅដល់កោះបាលី។

នោះគឺអភិជនក្មេង សិទ្ធិគុណ ។

ដោយមានបុរសមេកុលសម្ព័ន្ធធាត់កន្ទុក និងកូនចៅហែហមមកច្រើនសន្ធឹកផងនោះ នាយសិទ្ធិគុណ រឹងរឹតតែបញ្ចេញឫកពាក្អេងក្អាងគួរឲ្យទើសចិត្ត...។

ឪម៉ាលួចត្រិះរិះស្ងាត់ៗក្នុងចិត្តថា ហេតុអ្វីបានជានាយសិទ្ធិគុណស្ថិតនៅក្នុងចំណោមពួកម្ចាស់ស្រុកនេះដែរ ?... ឬមួយតាំងពីថ្ងៃនោះ... គេលួចគុំគួនរូបនាងទុក ហើយរង់ចាំឱកាសសងសឹកធ្វើបាបនាងឲ្យខាងតែបានឬអ្វី ?...

នាងនឹកឃើញភ្លាមពីហេតុការណ៍កាលពីល្ងាចម្សិល នាយសិទ្ធិគុណនេះមិនត្រឹមតែមុខក្រាស់ ចៃចង់នាងកណ្តាលថ្ងៃ គេថែមទាំងចិត្តធំ រហូតដល់ពោលប្រមាថនាងថាជាស្រីរបស់រាមនរិន្ទផង។ នៅឯកោះបាលីទៀតសោត គេប៉ងចាប់បង្ខំនាងកណ្តាលហ្វូងមនុស្ស បើកុំរាមនរិន្ទនៅទីនោះដែរ ម្ល៉េះសមនាងមិនដឹងជាក្លាយទៅជាយ៉ាងណាទៅហើយទេ... តែថ្ងៃនេះ... បុរសច្រឡើសបើសខ្វះសីលធម៌នេះ បង្ហាញខ្លួនលើនៅភូមិភូវីខាន់ស្ងាត់ៗគ្មាននរណាស្មានដល់.. ហើយឥឡូវលុកលុយដល់បន្ទប់រាមនរិន្ទទាំងយប់អាធ្រាត្រទៀតនេះ... គេពិតជាមានផែនការខ្មៅកខ្វក់អ្វីមួយហើយ ..។

នាងក្រមុំងាកមករកបុរសម្ចាស់ចិត្តទាំងក្តីបារម្ភពេញក្នុងគំនិត... តែនាងឃើញនរិន្ទរក្សាទឹកមុខស្មើថែស សម្លឹងទៅរកក្រុមមនុស្សដែលទើបមកដល់។..គេហើបមាត់ពោលស្រាលៗ តែច្បាស់ៗ ៖

- ប្អូនគុណ ! ចិត្តល្អមកលេងបងទាំងកណ្ដាលអាធ្រាត្រតែម្ដងហើយ ?

បុរសអភិជនក្មេងសិទ្ធិគុណ...ក្នុងឫកពាដ៏មានអំនួត...គេសើចរលាក់អស់ទាំងខ្លួន... ព្រមទាំងដើរមួយៗសំដៅមករករាមនរិន្ទផង។

កងការពារទាំងអស់របស់រាមនរិន្ទ ដកកាំភ្លើងពីចង្កេះស្ទុះមកពាំងពីមុខចៅហ្វាយនាយធ្វើឲ្យឌីម៉ាកាន់តែរន្ធត់ចិត្ត។ ក្រុមទាហានរបស់បុរសពុកចង្កាដែលនាងឃើញដង្ហែគ្នាកាលពីនៅកំពង់ផែសាមីក៏ស្ទុះមកប្រឈមមុខព្រមៗគ្នាជាមួយភាគីម្ចាស់បន្ទប់ដែរ។

អារម្មណ៍ស្រស់ស្រីឌីម៉ា ច្របូកច្របល់ខ្វល់ខ្វាយខ្លាំងជាងមុន ដោយឃើញថាពួកម្ចាស់ស្រុកលើកគ្នាមកច្រើនសន្ធឹកសន្ធាប់ណាស់... ជាហេតុឲ្យនាងស្មានទុកជាមុនថា... ម្ដងណេះរាមនរិន្ទនឹងមានគ្រោះថ្នាក់ជៀសមិនផុតទេ ។

ក្នុងខណៈ ដែលស្រស់ស្រីកំពុងខ្វល់ខ្វាយ... នាយសិទ្ធិគុណពោលទាំងសើចស្រស់មករកកូនប្រុសអ្នកនយោបាយ៖

- ឮថាបងរាមមានរបួស!... ពួកខ្ញុំគេងម៉េចលក់?

ឌីម៉ាងើបមុខសម្លក់ម្ចាស់វាចាស៊កសៀតដែលនាងស្គាល់ច្បាស់ពីសន្ដានចិត្តច្រឡោងខាមនោះច្បាស់។...នាងឃើញជននេះនិយាយទៅរករាមនរិន្ទ តែភ្នែកគេដៀងមករកស្រស់ស្រីជាប់...។ ក្រសៃភ្នែកដែលបង្កប់មកជាមួយនូវអត្ថន័យដ៏គួរឲ្យទើសចិត្តនោះ... ធ្វើឲ្យមាណវីឌីម៉ា ងាកមុខចេញទាំងខឹងណែនទ្រូង ។...

ភាគទី៣៨

សិទ្ធិគុណសើចស្វាញហាក់មិនអើពើចំពោះឫកពាមួហ្មងរបស់ធីតាយើងឡើយ... គេដើរចូលមករករាមនរិន្ទកាន់តែជិតជាងមុន...

- បងរាម របួសធ្ងន់ឬស្រាល ?... ឲ្យប្អូនសុំមើលផង... !

អង្គរក្សរឿន និងកងការពារជំនិតពីរនាក់ទៀតស្ទុះពាំងខ្លួនមកការពារម្ចាស់ប្រុស តែទាហានរបស់កុលសម្ព័ន្ធបានភ្ជង់មកតម្រង់ក្បាលពួកគេ...មុនពេលដែលពួកគេកម្រើកខ្លួននោះទៅទៀត...

រាមនរិន្ទមិនសម្លឹងសិទ្ធិគុណទៀតទេ...គេជៀងភ្នែកមករកបុរសធាត់កន្ទ្រលដែលជាម្ចាស់ស្រុក។ អ្នកកំលោះឃើញជននោះក្រញាត់ដៃងាកសម្លឹងទៅក្រៅបង្អួចធ្វើហី..។ អ្នកពោលទៅរកជននោះ... ដោយប្រើភាសាអង់គ្លេស ៖

- អូណ័រ!...ទីបំផុត...លោកសុខចិត្តល្មើសចំពោះខ្ញុំ... ព្រោះខ្ញុំមិនសមតាមបំណងលោកមែនទេ ?..

ជនពុកចង្កាប្រកាន់ភាពតោះតើយ...គេឆ្លើយតបវាហី ៖

- នៅទីនេះ... គេមិននិយាយរឿងល្មើសមិនល្មើសទេ ថៅកែរាម !... គេនិយាយតែរឿងផលប្រយោជន៍ !...

នរិន្ទរក្សាអាកប្បកិរិយានឹងន... គេពោលទាំងសម្លឹងម្ចាស់កុលសម្ព័ន្ធមិនដកភ្នែក ៖

- អញ្ចឹងពេលនេះ... លោកបានផលប្រយោជន៍អ្វីខ្លះ ?...

ជនម្ចាស់ស្រុកមិនទាន់បានតបផង....នាយសិទ្ធិគុណសើចកក្អឹកឆ្លើយតបជាភាសាខ្មែរ ព្រោះគេអាងថាអូណ័រមិនចេះស្តាប់ ៖

- ចាំបាច់សួរអីបង ?..ឲ្យតែលុយវាទៅ ប្រើវាធ្វើអ្វីក៏វាធ្វើដែរ អាពួកព្រៃរហាមដាច់ដាបនេះនុះ !...

រាមនរិន្ទ ដកភ្នែកចេញពីបុរសម្ចាស់ស្រុក ដែលកំពុងងឺងើព្រោះស្តាប់មិនបានថានាយសិទ្ធិគុណនិយាយអ្វីខ្លះ។...គេសម្លឹងមករកសិទ្ធិគុណដែលកំពុងច្រត់ចង្កេះសើចស្វាញចំពោះមុខខ្លួន។ ហាក់បានចិត្ត បុរសក្មេងញាក់ចិញ្ចើមនិយាយក្រអឺតដោយយល់ថាជ័យជម្នះកំពុងស្ថិតក្នុងកណ្តាប់ដៃខ្លួន ៖

-ខ្ញុំចំណាយពេលជាមួយពួកអស់នេះក៏មិនអត់អំពើដែរ! ទីបំផុតនៅតែអាចកុហកសូម្បីតែបងរាម! គួរឲ្យអស់សំណើចដែរដែលបងឯងឆ្លាតយូរហើយមកលង់ម្តង ចាញ់បោកថាឥន្ទប្បដិមានៅក្នុងដៃពួកជ្រូកព្រៃអស់នេះ!

រាមនរិន្ទបង្ហាញភាពហួសចិត្តលើបប្អូរមាត់។ អ្នកកំលោះយើងវាចាចេញនូវប្រយោគត្រជាក់ស្រិប៖

- លោកពូ ឆាយណៈគុណ គ្មានសំណាងមែនដែលបានកូនគ្មានប្រយោជន៍ដូចឯង !

បបូរមាត់សិទ្ធិគុណរុះរោយបាត់នូវស្នាមញញឹមដ៏ច្រឡើសបើស ជំនួសមកវិញនូវភ្លើងកំហឹងជះចេញព្រាកៗពីកែវភ្នែកទាំងគូរបស់គេ។ ដែលគួរឲ្យក្តៅចិត្តបំផុតនោះ គឺរាមនរិន្ទមិនស្គាល់កាលៈទេសៈមិនយល់ថាខ្លួនឯងកំពុងយោងអាត្មាមិនទាំងរួច ហ៊ានមកដៀលគេនៅនឹងមុខស្រីស្អាតទៀត។

គេដើរចូលមករករាមនរិន្ទ ធ្វើឲ្យស្រស់ស្រីឪម៉ាភ័យស្លន់ស្លោក្នុងចិត្ត។

រំពេចដែលនាងក្រមុំរកគិតមិនទាន់ថា ជនខ្វះសីលធម៌នេះ នឹងមានប្រតិកម្មយ៉ាងណាចំពោះពាក្យអសុរស ដែលរាមនរិន្ទផ្តល់ឲ្យនោះ...ហេតុការណ៍អកុសលបានកើតឡើងលឿនជាងការគិតទុករបស់នាងទៅទៀត... ព្រោះសិទ្ធិគុណបានងាកទៅទាញកាំភ្លើងវែងមួយពីក្រុមទាហានម្ចាស់ស្រុកដែលឈរខាងគេ...។ បុរសខ្មែរឈាមរាវក្តាប់អាវុធយ៉ាងណែនក្នុងដៃទាំងពីរ។ គេញាក់ចិញ្ចើមព្រមជាមួយនឹងស្នាមញញឹមយ៉ាងសាហាវ មុនពេលនិយាយគំរោះគំរើយមកកាន់កំលោះម្ចាស់បន្ទប់៖

- ចុះឯងដឹងថា កូនអត់ប្រយោជន៍ដូចអញនេះ នឹងជួយព្យាបាលឯងយ៉ាងម៉េចទេ ?...

ជាមួយនឹងវាចាអសុរស...គេលើកស្ទួយកាំភ្លើងបុកសំដៅដើមទ្រូងរាមនរិន្ទត្រង់បង់រុំ ដែលគេសម្គាល់ថាជាកន្លែងរបួសមិនទាន់ជានោះ...។

ឪម៉ាស្រែកយ៉ៃដោយតក់ស្លុត..នាងស្ទើរគាំងបេះដូងស្លាប់ចំពោះកាយវិការព្រៃផ្សៃនេះ ...។

នាងបើកភ្នែកធំៗមើលទៅនាយរឿន បានក្រឡាស់ខ្លួនលើកដៃរងស្ទួយកាំភ្លើងជំនួសរាមនរិន្ទ ធ្វើឲ្យខ្លួនឯងបាត់ជំហរផ្កាប់មុខដួលទៅលើគ្រែ។...

ដោយរឹតតែក្រពុលមុខ ដែលមិនបានធ្វើឲ្យរាមនរិន្ទឈឺចាប់...ម្តងណេះសិទ្ធិគុណលើកស្ទួយកាំភ្លើង វាត់សំដៅក្បាលអង្គរក្សរឿនតែម្តង ទាំងភ្លើងកំហឹងភ្លាត់ចេញតាមមាត់ផង ៖

- គ្រាប់បើផងអ្ហែស៎ អាខ្ញុំបម្រើ ?...

នាយរឿន ដែលត្រូវស្ទួយកាំភ្លើងវាត់ចំដើមដៃ និងស្នាទ្បើងខៀវមុខដោយការឈឺចាប់ទៅហើយនោះ គ្មានជម្រើសអ្វីក្រៅពីនៅរងកំហឹងជំនួសចៅហ្វាយទេ...តែរាមនរិន្ទម៉េចនឹងបណ្តោយឲ្យកូនចៅស្លាប់ជំនួសខ្លួនកើត...គេរុញនាយជំនិតចេញយ៉ាងរហ័ស... បណ្តាលឲ្យស្ទួយកាំភ្លើងដែលវាត់មកជាលើកទីពីរនេះទង្គិចទៅនឹងគែមគ្រែលាន់ឆាំង។ ឪម៉ាស្រែកដោយរន្ធត់ ប៉ុន្តែជនឈ្មោះអួណ៍រនៅតែឈរមើលធ្វើហី មិនខ្វីបញ្ជាឲ្យទាហានខ្លួនទម្លាក់អាវុធទេ ព្រោះហាក់ចង់ទុកឲ្យនាយសិទ្ធិគុណអាចធ្វើអ្វីៗបានតាមអំពើចិត្ត ។

សិទ្ធិគុណ វាត់ស្ទួយកាំភ្លើងមកជាលើកទីបី ប្រាថ្នាវាយរាមនរិន្ទឲ្យខាងតែបាន... តែគេត្រូវដកមកវិញស្ទើរមិនចង់ទាន់... ព្រោះម្តងណេះកូនចៅកូនប្រុសអ្នកនយោបាយដែលត្រូវគេភ្ញង់អស់គ្មានអ្នក

ណាអាចចូលមករងជំនួសចៅហ្វាយប្រុសទៀតទេ...គឺមានតែរាងកាយល្វតល្វន់នៃស្រីស្អាតដែលស្ទុះមកទ្រោបពីលើរាមនរិន្ទតែម្ដង ..។

ក្នុងមួយប៉ប្រិចភ្នែក អ្នកប្រុសធំមកពីគ្រួសារអ្នកតំណាងរាស្ត្រស្រវាឱបរាងកាយតូចតន់ទាំងក្ដុកក្ដួលចិត្តដោយសារគេគិតថានាងមុខជាត្រូវទទួលមួយស្វ័យកាំភ្លើងដ៏ដំណំនេះ...គ្មាននរណាស្មានដឹងទេថាសិទ្ធិគុណត្រូវបង្ខំដកដៃវិញទាំងបែកញើសសស្រាក់។

ឌីម៉ាបើកភ្នែកវិញ ដែលអម្បាញ់មិញនាងប្រឹងបិទដើម្បីទទួលទណ្ឌកម្មជំនួសម្ចាស់ចិត្ត។ ដឹងថាមិនទាន់មានរឿងអ្វីកើតឡើងនៅឡើយ...នាងក្រមុំបែរក្រោយស្រែកដាក់សិទ្ធិគុណទាំងញ័រមាត់តតាក់៖

-ចង់ធ្វើអីគាត់ ?

នាយអភិជនច្រឡើសបើសដែលកំពុងក្រពុលមុខក្នុងភាពឃោរឃៅ...បែរជាស្រាយទឹកមុខមកវិញ។... គេសើចក្អាកក្អាយហើយងក់ក្បាលផ្ងក់ៗផង ៖

-បើដឹងថាវាយអាចង្រៃនេះ...មានគេព្រមនិយាយរកយើងនោះ...យើងចាត់ការវាយូរណាស់ហើយ!...

ឌីម៉ាណាខឹង ណាហួសចិត្តចំពោះអាកប្បកិរិយាឆ្កួតលីលារបស់បុរសក្មេងច្រឡើសបើសនេះ...នាងបន្លឺឡើងទាំងយំសស្រាក់ ៖

- ចេះគិតអត់ ?... មកកាប់សម្លាប់គ្នាមុខជនបរទេសទៅកើត ?

សិទ្ធិគុណបញ្ចេញវាចាហាក់គ្មានការអៀនខ្មាស ៖

-យើងក៏ចង់ឲ្យនាងដឹងថា... រវាងមនុស្សមិនចេះគិតដូចយើង និងអាម្សៀគ្មានបានការនេះ... តើអាណាមួយអាចការពារនាងបាន ?

អភិជនច្រឡើសបើសឱនមកទាញដៃស្រស់ស្រី...កន្ត្រាក់ចេញពីរាមនរិន្ទទាំងងងើល៖

- កេតឌីម៉ាអើយកេតឌីម៉ា មួយជីវិតនេះ ស្មានថាគេចពីយើងរួចអ្ហេស៎ ?...

តរុណីកន្ត្រាក់ដៃបុរសដែលក្មេងជាងនាងចេញទាំងខឹងពេញទ្រូង...តែនាយច្រឡើសបើសសិទ្ធិគុណនេះចាប់ដៃស្រស់ស្រីជាប់ មិនឲ្យរបូតងាយឡើយ...។

ក្នុងបំណងបញ្ឈឺចិត្តរាមនរិន្ទ ដោយសំអាងថាខ្លួនជាអ្នកមានប្រៀបនោះ...សិទ្ធិគុណឈ្ងោកមុខមកថើបថ្ពាល់ស្រស់ស្រីទាំងងើល។...នាងក្រមុំអ្នកបង្ហាញម៉ូត ឈ្ងោកមុខផ្ទឹបទៅនឹងរាងកាយរាមនរិន្ទ គេចចេញពីអំពើច្រឡេងខាមនៃមនុស្សពាលរូបនេះ ជាហេតុធ្វើឲ្យសិទ្ធិគុណមួហ្មងជាងមុន...។

គេទាញកន្ត្រាក់មាណវីឲ្យឃ្លាតចេញពីរាមនរិន្ទដោយឈ្ងោកមុខទៅជាលើកទីពីរ ..។

តែម្តងនេះ...មិនមែនផែនថ្ពាល់មាណវីរូបល្អទេ ដែលត្រូវរងច្រមុះគេនោះ...គឺកាណុងកាំភ្លើងខ្លីដ៏រឹង និងត្រជាក់ស្រិបកំពុងភ្ជង់កូនប្រុសអ្នកឧកញ៉ាជាប់ចំកណ្តាលថ្ងាសតែម្តង ...។..

សិទ្ធិគុណភ្ញាក់ព្រើត ដូចទើបស្វាងពីយល់សប្តិ...ទឹកមុខស្មើថៃសរបស់រាមនរិន្ទ នៅចំពោះមុខខ្លួន....ជាសញ្ញាដាស់បុរសច្រឡើសបើសឲ្យស្តាយក្រោយដែលខ្លួនមើលស្រាលរាមនរិន្ទកាលពីពេលមុននេះ ។..

គេមិននឹកស្មានដល់ថា...ការដែលគេឈ្ងោកមកក្បែរបុរសម្ចាស់បន្ទប់... គឺហាក់បីដូចជារុញក្បាលបញ្ចូលមាត់ខ្លាអញ្ចឹងដែរ...។

ឪម៉ាដែលកំពុងភ័ន្តភាំង កាលបើស្មានមិនដល់ថា... រាមនរិន្ទមានកាំភ្លើងក្បែរខ្លួននោះ... បានភ្ញាក់អារម្មណ៍ និងងើបមុខមកវិញ... នៅពេលឮបុរសកំពូលដួងចិត្តបន្លឺវាចាស្មើថៃស ៖

- ឯងចូលចិត្តអារបៀបអស់នេះហ្អីសិទ្ធិគុណ?...កំដរឯងបានទេតើ!

ឪម៉ាសម្លឹងទៅរកសិទ្ធិគុណទាំងរន្ធត់ចិត្ត... នាងក៏មិនអាចសន្មតបានដែរថា... រាមនរិន្ទនឹងកេះកែកម្ទេចក្បាលជននោះឬយ៉ាងណា...តែនាងឃើញថាយុវជនឈាមរាវកំពុងញ័រទទ្រើកចំពោះមុខផ្លូវមច្ចុរាជជាស្រេចទៅហើយ ...។...ស្រស់ស្រីដកដៃចេញពីម្រាមដៃត្រជាក់ស្រិបដូចទឹកកករបស់គេដែលមុននេះមិនព្រមលែងនាងជាដាច់ខាតនោះ...។

នាងងើបអង្គុយកាលណាក៏ឃើញកងការពារនាយសិទ្ធិគុណបើកភ្នែកក្រឡោតសម្លឹងមករាមនរិន្ទដោយកំហឹង ...។ កូនប្រុសអ្នកនយោបាយដៀងភ្នែកសម្លឹងទៅកាន់ក្រុមអ្នកលេងដោយពោលសង្កត់ពាក្យធ្ងន់ៗ ៖

- បើមិនដាក់កាំភ្លើងទេ.. !.. ក្បាលវានឹងស៊ីគ្រាប់សំណនេះហើយ !...

ក្នុងពេលដែលកូនចៅសិទ្ធិគុណកំពុងទីទើរនោះ... រាមនរិន្ទរើខ្លួនក្រោកដោយទាញកអាវអភិជនច្រឡើសបើសឲ្យក្រោកមកជាមួយផង ...។...

ឱម៉ាភ្ញាក់រួចទៅជាភ័ន្តភាំង..កាលបើឃើញរាមនរិន្ទ នៅឈររឹងប៉ឹងកណ្ដាលបន្ទប់ហាក់បីដូចជាគេពុំបានរងរបួសអ្វីសោះយ៉ាងដូច្នោះ... ។

សំឡេងបុរសពុកចង្កាស្រែកខ្ទរបន្ទប់ ៖

- លែងទៅ !...?... លែងគេភ្លាម !...

រាមនរិន្ទសើចស្ងួត... គេពោលតបវិញជាភាសាបរទេស ៖

-លោកក៏មិនរួចខ្លួនដែរអូណ័រ!...លោកស្មានថាការដាក់គ្រាប់បែកនៅ Winter Jaya Pura អាជ្ញាធរហ្សាកាតាអត់ដឹងអីសោះ?..ខ្ញុំគិតថាពេលនេះគេកំពុងមកដល់កំពង់ផែសាមីហើយ... យូរបំផុត ២០នាទីទៀត គេនឹងបានឃើញថា... លោកអនុវត្តន៍ច្បាប់យ៉ាងម៉េចនៅភូមិរបស់លោក...!...

ជនកន្ទាត់ថ្លោះទឹកមុខ...។ ចំណែកសិទ្ធិគុណដែលមិនដឹងរឿង ពោលសួរដោយសង្ស័យ៖

-ស្អីគេ? គ្រាប់បែកស្អី?

រាមនរិន្ទងាកមករកសិទ្ធិគុណសាជាថ្មី... គេរុញកាំភ្លើងទៅបុកនឹងថ្ងាសជននោះខ្លាំងជាងមុន... ជាហេតុធ្វើឲ្យកេតឱម៉ាស្ទុះមកក្បែរទាំងមិនដឹងខ្លួន។ អ្នកកំលោះងាកមកសម្លឹងមុខនារីគូស្នេហ៍អត្តន័យហាមឃាត់ស្ដែងចេញតាមរយៈទឹកមុខនាង...បង្ហាញថា...នាងមិនចង់ឲ្យអ្នកសម្លាប់សិទ្ធិគុណទេ....គ្រាន់តែនាងមិនហ៊ានហារចេញមកប៉ុណ្ណោះ។ គេងាកមកមើលសិទ្ធិគុណវិញ... ម្ដងនេះអ្នកឃើញយុវជនកំហូចញ័រខ្លួនទទ្រើកញើសហូរដូចទឹក... គេបន្លឺដោយតក់ស្លុត តែឥតអៀនខ្មាស ៖

- បងរាម !...កុំ...កុំ..!...កុំបងរាម!..

សំឡេងមួយលាន់មកពីមាត់ទ្វារ៖

-អាចង្រៃវាយក៍!

គ្រាប់ភ្នែកនាយសិទ្ធិគុណត្រូវក្រឡឹងចុះឡើងដោយភ័យរន្ធត់។ គេប្រហែលស្គាល់សំឡេងបុរសដែលទើបតែឡើងមកដល់។ បុរសទឹកមុខថ្លៃថ្នូរដោយមានទាហានឥណ្ឌូណេស៊ីមួយក្រុមឡើងមកតាមពីក្រោយផងនោះ បានដើរចូលមកដោយរលះរលាំង។

រាមនរិន្ទដកកាំភ្លើងចេញពីថ្ងាសយុវជនឈាមរាវ ឃើញដូច្នោះកងការពារសិទ្ធិគុណស្ទុះមករកជួយចៅហ្វាយខ្លួនដែលកំពុងស្វាយមុខចំពោះកាណុងកាំភ្លើង។

ភាសាថៃរបស់នាយសិទ្ធិគុណបន្លឺចេញជាដំបូងបង្អស់ទៅកាន់បុរសចំណូលថ្មី៖

-លោកមា!

នាយរឿន និងគ្នីគ្នាក្រោកឈរវិញចម្មតា ឯបុរសដែលទើបបង្ហាញខ្លួនប្រឹងសើចទាំងបង្ខំ ហើយឱននិយាយគួរសមដាក់រាមនរិន្ទ៖

-អ្នកប្រុសរាមនរិន្ទកុំប្រកាន់វាអី! ប៉ាវាដឹងរឿងអស់ហើយ! គាត់ពិបាកចិត្ត នឹកខ្លាចចិត្តអ្នកប្រុសខ្លាំងណាស់! ខ្ញុំព្ទដំណឹងពីម្សិលមិញខំឡើងទូកមកភ្លាមទាំងខ្យល់ព្យុះ អ្នកប្រុសយោគយល់ កុំឲ្យជ្រាបដល់ឯកឧត្តមអីទាន!

សិទ្ធិគុណក្រោកឈរដោយទឹកមុខខ្មៅរោល ចរិតច្រលើសបើសនៅតែមិនចោលនិស្ស័យ៖

-គាត់ភ្ជង់ចង់បាញ់ក្បាលខ្ញុំមុន.... ហើយ....

បុរសចំណាស់ងាកមកសម្លុតក្មួយប្រុសមិនឲ្យគេអាចនិយាយបន្តទៀតបាន៖

-សុំទោសគាត់អាគុណ! ឲ្យលឿន លោកប៉ាឯងកំពុងចាំនៅបាលី!

ស្នូរទូរសព្ទលាន់ឡើងយ៉ាងគ្រលួច...កាត់ផ្តាច់ភាពស្ងាត់ជ្រងំរបស់រាត្រីកាល..។.. បុរសរូបរាងធាត់ឈ្មោះអូណ័រលើកទូរសព្ទមកស្តាប់..។.. ទឹកមុខប្រែប្រួលយ៉ាងរហ័សរបស់ម្ចាស់ស្រុក បានធ្វើឲ្យរាមនរិន្ទ ដឹងជាស្រេចទៅហើយថាម្នាក់នោះក៏កំពុងវ័ណ្ឌកដែរ។

គេងាកទៅរកសិទ្ធិគុណ ឃើញយុវជនងប់ស្នេហ៍កំពុងចចេសនៅចំពោះមុខលោកមា ដែលហាក់យល់ការជាងនោះ រាមនរិន្ទដកដង្ហើមយូរនិយាយសម្របសម្រួល៖

-លោកពូគា! នាំសិទ្ធិគុណទៅឲ្យហើយទៅ ពួកម្ចាស់ស្រុកនេះ មានពាក់ព័ន្ធរឿងផ្ទុះគ្រាប់បែកនៅកន្លែងដេញថ្លៃនៅចាយ៉ាពូរ៉ាផង កុំឲ្យប៉ូលិសឆ្លងទឹកមកទាន់នាំតែមានជាប់រឿងរ៉ាវអត់ប្រយោជន៍!

បុរសថៃបើកភ្នែកធំៗដោយភ្ញាក់ផ្អើល។ គាត់និយាយដោយឱនលំទោន៖

-អ្នកប្រុសជួយទៀតហើយ! អរគុណណាស់!

គាត់លើកដៃវាយក្បាលក្មួយប្រុសផូងកណ្តាលចំណោម ហើយសម្លុត៖

-ឯងនេះ! អាគុណ? រកស៊ីមិនចេះ! ការងារឪពុកម៉ាគគោកមិនជួយ គិតតែនាំរឿង! ទៅផ្ទះវិញភ្លាម!

ជនចំណាស់អូសនាំក្មួយទៅដោយស្តីបន្ទោសចប់តាមផ្លូវ៖

-ឯងធ្វើអីខ្លះនៅបាលី? ភាគហ៊ុនផ្សេងៗគេនិយាយច្រើនណាស់រឿងឯងអុកឡុកភ្ញៀវ ដេញគេចេញពីហាង ប៉ាឯងគាត់ឈឺក្បាលណាណីហើយ! គាត់ច្បាស់បញ្ជូនឯងទៅអាមេរិកហើយ!

-អត់ទេលោកមា! ជួយនិយាយខ្ញុំផង ខ្ញុំអត់ទៅអាមេរិកទេ!

សំឡេងនាយសិទ្ធិគុណកាន់តែដាច់ឆ្ងាយទៅ រាមនរិន្ទងាកទៅអ្នកដែលនៅសល់។ នាយឃើញបុរសកន្ទាត់ក្រោយពីស្តាប់ទូរសព្ទចប់...ក៏ងាកឲ្យសញ្ញាដល់គ្នីគ្នារួចនាំគ្នាចាកចេញពីបន្ទប់រាមនរិន្ទយ៉ាងរហ័សតាមលំនាំរបស់សិទ្ធិគុណដែរ។...

នាយគង់ និងនាយរឿនស្ទុះស្ទាមកគ្រាថៅហ្វាយដែលចាប់ផ្តើមបង្ហាញការឈឺចាប់លើផ្ទៃមុខ។ ឌីម៉ាដឹងថា កាលដែលគេប្រឹងក្រោកឈរធ្វើឲ្យប៉ះពាល់ច្បាស់ណាស់ដល់មុខរបួសដែលទើបតែរៀបរយកាលពីប៉ុន្មានម៉ោងមុននេះ។ សំឡេងគេពោលស្រាលៗទៅរកអង្គរក្សជំនិត៖

-មិញនេះ សិទ្ធិគុណវាយត្រូវកន្លែងណាខ្លះរឿន?

ឌីម៉ាទើបតែនឹកឃើញដល់មនុស្សជំនិត ដែលមុននេះបានរងស្វ័យកាំភ្លើងជំនួសប្រុសស្នេហ៍។ នាងងាកមើលទៅគេដោយស្ងប់ស្ងែងចំពោះភក្តីភាពមនុស្សជំនិត។

ជាមួយនឹងទឹកមុខនឹងនរ អង្គរក្សពិសេសតបវិញរួសរាន់៖

-ខ្ញុំអត់អីទេអ្នកប្រុស! យើងគួរចេញពីកន្លែងនេះហើយ!

រាមនរិន្ទងក់ក្បាល ធ្វើឲ្យនាងក្រមុំដើរយឺតៗមកគ្រាគេ ឯពួកអង្គរក្សក៏លែងដៃពីនាយថៅហ្វាយ ព្រោះគេដឹងថានាយត្រូវការនាងជាង។ នៅពេលដែលមនុស្សម្នានាំគ្នារៀបចំសម្ភារៈប្រញិបប្រញាប់ ដើម្បីចាកចេញត្រឡប់ទៅរកកប៉ាល់ ឌីម៉ាដើរបណ្តើរ សួរនាំប្រុសស្នេហ៍បណ្តើរ៖

-លោកឈឺយ៉ាងហ្នឹងហើយ នៅមិនគិតខ្លួនក្រោកមកតតាំងគេទៀត?

រាមនរិន្ទញញឹមទាំងផ្តេកក្បាលលើស្មានាងក្រមុំ... មាត់ពោលតប ៖

- បើគ្រាប់កាំភ្លើងមួយគ្រាប់អាចធ្វើឲ្យរាមនរិន្ទដេកស្ងៀមបាននោះ... ម្ល៉េះបងមិនត្រូវប្រគល់ស្រីដែលបងស្រលាញ់ឲ្យទៅសិទ្ធិគុណ និងពួកម្ចាស់ស្រុកទៅហើយ ?

នាងញញឹមសម្លឹងគេដោយពន្លឺភ្នែកស្រទន់។ ពិតណាស់ប្រសិនបើអម្បាញ់មិញ អ្វីៗមិនអាចគ្រប់គ្រងបាន នាងច្បាស់ជាមានបញ្ហាដោយសារតែចរិតឈាមរាវរបស់បុរសខ្មែរវ័យក្មេងនោះ ហើយរាមនរិន្ទដែលមិនសុខចិត្តឃើញនាងត្រូវគេធ្វើបាប ក៏មិនដឹងថានឹងជួបរឿងអីនោះដែរ។

ហេតុការណ៍ស្រាប់តែងាកមកដោះស្រាយបានហាក់ធូរៗ ធ្វើឲ្យធីតាយើងមិនទាន់អស់ចម្ងល់ងាយទេ នាងសួរគេវិញ៖

-លោកទូរសព្ទទៅទាក់ទងចាស់ទុំរបស់សិទ្ធិគុណមែនទេ?

រាមនរិន្ទញញឹមនឹងន គេតបសំនួរស្រីស្នេហ៍៖

-បងគ្រាន់តែឃើញសិទ្ធិគុណនៅចម្ការ ដឹងថាគេមានបញ្ហាហើយ! ចំណែកតាអូណ៍រសុខៗបង្ហាញខ្លួន ប្រាកដជាមិនមែនធម្មតា ប៉ុន្តែគេដឹងរឿងឥន្ទប្បដិមាច្រើនពេករហូតដល់បងមិនដាច់ចិត្តថាមិនជឿ មិននឹកស្មានថា របស់ដែលគេឲ្យបងឃើញកាលពីព្រឹកមិញជារបស់ក្លែងក្លាយសោះ!

-ចុះម៉េចលោកដឹងថាពួកគេជាអ្នកដាក់គ្រាប់បែកនៅចាយ៉ាពូរ៉ា? (នាងសួរបន្ថែម)

បុរសឆ្លើយទន្ទឹមនឹងពេលឈានជើងចុះជណ្តើរតិចៗ៖

-យើងមិនគិតដល់រឿងហ្នឹងទេ តែពេលយើងលួចស្តាប់ការទាក់ទងរបស់ពួកគេតាមទូរសព្ទ បានយើងដឹងពីរឿងហ្នឹង! គ្រាន់បើដែរ ដែលអ្វីៗនៅមិនទាន់យឺតពេល។

នាងគ្រាគេចុះទៅក្រោមទាំងមិនមានចេញស្តីអ្វីបន្ថែមទេ ព្រោះមិនចង់ឲ្យគេដែលកំពុងឈឺចាប់ដោយមុខរបួសត្រូវទ្រាំទ្រឆ្លើយតបនឹងសំនួរខ្លួនច្រើន ប៉ុន្តែក្នុងចិត្តនាងនៅតែនឹកមិនអស់ចិត្តថា ហេតុអ្វីមនុស្សនៅភូមិភូវីខាន់ចាំបាច់បង្កបន្ទុះនៅកន្លែងដេញថ្លៃ? គេដូចជាដឹងរឿងទាក់ទងនឹងឥន្ទប្បដិមានោះច្រើនណាស់អញ្ចឹង? នៅសុខៗម៉េចក៏គេនឹកឃើញមកបោកប្រាស់រាមនរិន្ទ ហើយលួចទាក់ទងជាមួយនាយសិទ្ធិគុណទៀត?

ភាគទី៣៩

## វគ្គទី១៨

## កិច្ចសន្យាស្នេហ៍

កប៉ាល់អណ្តែតយឺតៗសាជាថ្មីលើទន្លេម៉េមប៊ីរ៉ាម៉ូ។ ព្រះអាទិត្យរាងរះដូចសព្វមួយដង នាំមកជាមួយនូវថ្ងៃថ្មីដែលតែងតែជាក្តីសង្ឃឹមថ្មីសម្រាប់មនុស្សម្នានៅលើផែនដីនេះ។ នាយBirdឈរពត់ខ្លួន រួច

សម្លឹងទៅចរន្តទឹកហូរដោយស្ងប់ស្ងាត់ម្នាក់ឯង គ្មាននរណាដឹងថាតើក្នុងចិត្តជនបង្កប់កំពុងគិតពីរឿងអ្វីនោះទេ ប៉ុន្តែឆ្លងកាត់រឿងជាច្រើន រាប់ចាប់តាំងពីកោះបាលីមកដល់ចាយ៉ាពូរ៉ា ហួសរហូតដល់ភូមិភូរីខាន់នៅស្រុកសាមី នាយBirdកាន់តែប្រែប្រួលអាកប្បកិរិយាទៅជាស្រងេះស្រងោចរកស្មានមិនដល់។ ឈរនៅកន្សែទូកម្នាក់ឯងដោយដកដង្ហើមធំម្តងៗ នាយអង្គរក្សសួរខ្លួនឯងជាមួយសំនួរថាតើខ្លួនកំពុងទៅណាហើយនិងកំពុងធ្វើអ្វី?

សម្រិបជើងនាយរឿនលាន់មកពីក្រោយខ្នង ធ្វើឲ្យជនបង្កប់ផ្លាស់ទឹកមុខឲ្យរៀបរយជាងមុន ងាកទៅញញឹមទទួលមេកើយ។

-បងរឿន! យប់មិញលាបប្រេងហើយបានធូរច្រើនអត់?

នាយរឿនឈរមកក្បែរគូកនដោយនិយាយទាំងទឹកមុខមាំទាំ៖

-គ្មានអីធំដុំទេ! ម្នាក់ៗម៉េចក៏ចាប់អារម្មណ៍សួរតែពីរឿងហ្នឹងម្ល៉េះ?

នាយBridសើចបន្លប់ ទើបពោលបន្ត៖

-ត្រូវនឹងស្ន៍យកាំភ្លើងហើយនៅអត់ធំដុំទៀត?

នាយរឿនសើចស្ងួត បែរសម្លឹងទៅផ្ទៃទឹកហើយបណ្តោយឲ្យសន្ទឹកខ្យល់ផាត់បំបើុងអាវ និងសក់យ៉ាងមានសុខដុម។ អង្គរក្សរាងវៃនិយាយតបសម្តីនាយBrid៖

-ជីវិតជាអ្នកការពារ ជាអ្នកកាន់កាំភ្លើង មានអីអស្ចារ្យប៉ុណ្ណឹងៗ?

គេឈប់បន្តិច ក៏និយាយបន្តក្រោមខ្សែភ្នែកសញ្ជឹងគិតរបស់នាយBird៖

-សំខាន់បើអ្នកប្រុសជាអ្នករបួសវិញខ្ញុំឈឺចាប់ជាងនេះ!

នាយBirdចងចិញ្ចើមមិនចេញស្តី តែគេលួចដណ្តឹងសួរក្នុងចិត្ត៖

-លើលោកនេះមានមនុស្សសុខចិត្តឈឺខ្លួនជំនួសគេអញ្ចឹងដែរ?

គេរេភ្នែកត្រិះរិះម្នាក់ឯងបន្តថា ចុះបើក្នុងករណីខ្លួននៅក្បែរថៅហ្វាយដើម គឺអភិជនKenហើយនាយនោះជួបគ្រោះថ្នាក់ដូចករណីរបស់រាមនរិន្ទកាលពីយប់ តើខ្លួននឹងសុខចិត្តប្រថុយជីវិតជំនួសគេដែរឬយ៉ាងណា។ សំឡេងនាយរឿនលាន់មកវិញតិចៗ៖

-មនុស្សដូចអ្នកប្រុសរាម បើទុកឲ្យមនុស្សអាក្រក់ធ្វើបាបបាន ទើបគួរឲ្យស្តាយក្រោយបំផុត!

នាយBirdធ្វើជាញញឹមតិចៗហើយឆ្លើយតប៖

-ខ្ញុំត្រូវរៀនពីបងរឿនច្រើនទៀត!

អង្គរក្សរឿនគ្រវីក្បាល គេបន្តតិចៗ៖

-អត់ទេ! រៀនពីអ្នកប្រុសទៅ! យើងជាបរិវារ ការពារជីវិតចៅហ្វាយជាការងារទៅហើយ តែចៅហ្វាយម្នាក់ដែលលោតទឹកទៅជួយជីវិតអ្នកបម្រើដូចយើងទើបវាចម្លែក! ទោះអ្នកប្រុសរាមជាកីឡាករហែលទឹកប្រចាំសាលា តែកាលថ្ងៃឯងធ្លាក់ជ្រូកនោះ អ្នកប្រុសរបួសដៃស្តាំទៅហើយ បើជាឯង ឯងព្រមប្រថុយលោតទឹកទៅស្រង់អង្គរក្សម្នាក់ទេ?

នាយរឿនបែរខ្នងចាកចេញទៅ ទុកឲ្យជនបង្កប់នៅស្រងល់តែម្នាក់ឯង។ គេឈ្ងោកមុខក្នុងស្ថានភាពពាក់កណ្តាលពិបាកចិត្ត និងពាក់កណ្តាលរារែក។ ចូលមកនៅក្បែររាមនរិន្ទទើបតែមួយឆ្នាំប៉ុន្មានខែ ប៉ុន្តែគេយល់ថាមានភាពខុសគ្នាច្រើនអនេករវាងនាយKen និងកូនប្រុសអ្នកនយោបាយ។ ប៉ុន្តែទោះយ៉ាងណាគុណសង្គ្រោះជីវិត និងអំពើល្អដែលបង្ហាញចេញមកជាធម្មជាតិរបស់តួឯកប្រុសយើង បានធ្វើឲ្យនាយBirdគិតសាជាថ្មីពីផែនការអនាគតរបស់ខ្លួន។

គេដើរកាត់ពីមុខបន្ទប់សាឡុងក៏ប្រទះឃើញស្រីស្រស់ឌីម៉ាកំពុងនៅចាំទាំងបម្រើអាហារពេលព្រឹកដល់បុរសសង្ហា ដែលនៅទន់ខ្សោយដោយមុខរបួសនៅឡើយ។ អង្គរក្សបង្កប់ខ្លួនជ្រួញចិញ្ចើមដោយតានតឹងចិត្ត គេសួរខ្លួនឯងបន្ត៖

“ចុះតើមានអ្វីកើតឡើង បើរាមនរិន្ទនៅតែមិនដឹងពីសមាសភាពពិតរបស់កេតឌីម៉ា? ហើយចុះបើថ្ងៃណាមួយគេត្រូវស្លាប់ដោយដៃស្រីម្នាក់នេះ តើអាត្មាអញនឹងអាណិតគេ ហើយមានវិប្បដិសារីដែរអត់?”។

នាយBirdក៏មិនដឹងដែរថាបេះដូងស្រីស្អាតបានចុះចាញ់ចំពោះស្នេហាស្មោះស្ម័គ្ររបស់បុរសសង្ហាទៅហើយ។ នាយនៅតែស្មានខុសថាគ្រប់កាយវិការល្អៗរបស់កេតឌីម៉ាគឺស្ថិតក្នុងផែនការរបស់នាយKenនៅឡើយ ព្រោះនាយBirdមិនបានដឹងពីរឿងដែលថាកេតឌីម៉ាបានស្គាល់សារជាតិពិតរបស់ប្រុសស្នេហ៍សម្បូរល្បិចរបស់នាងនៅក្នុងកាលៈទេសៈបន្ទុះនៅចាយ៉ាពូវ៉ារួចទៅហើយនោះទេ។

ចាប់ពីពេលនោះមក គេត្រូវបានដាច់ការទាក់ទងពីនាយKenទាំងស្រុង ដោយសាររាល់មធ្យោបាយទំនាក់ទំនងទាំងឡាយត្រូវបានដកហូតអស់ បន្ទាប់ពីនាយរឿនរកឃើញការលេចធ្លាយព័ត៌មានពិធីដេញថ្លៃនោះមក។

នាយBirdដើរហួសចាកចោលបរិយាកាសល្អកល្អើនរបស់គូស្នេហ៍មួយគូនេះ ប៉ុន្តែគេបានស្ពាយជាប់ទៅជាមួយនូវសម្ពាយចំណោទដ៏ធ្ងន់មួយ។

តើជនបង្កប់ចុងក្រោយរបស់ពាណិជ្ជករដែកថែប អាចលើកទង់ជ័យស ចុះចូលជាមួយសត្រូវខ្លួនតាមការបង្ខំរបស់សម្បជញ្ញៈដែរឬយ៉ាងណា? គ្មានអ្នកណាអាចធ្វើកិច្ចសន្យាដាក់ការធានាលើបេះដូងមនុស្សដែលមានឈាមរត់ចុះឡើងជានិច្ចនោះទេ រហូតដល់ពាក្យមួយត្រូវបានគេទទួលស្គាល់ជាទូទៅនោះគឺថា លោកនេះគ្មានអ្វីទៀងទាត់ឡើយ។

នៅឯកោះស្មៅលឿងដែលជាគោលដៅចុងក្រោយនៃក្រុមអ្នកផ្សងព្រេង នាយKenនិងលំអងកំពុងប្រឈមជាមួយចំណោទមួយថ្មីទៀត។

តើរយៈពេលដែលពាណិជ្ជករដែកថែបបានរួមដៃជាមួយសិទ្ធិគុណក្នុងការបង្កើតអន្ទាក់នៅស្រុកសាមីដើម្បីបង្អាក់ដំណើររាមនរិន្ទកុំឲ្យបានមកកោះស្មៅលឿងទាន់ដំណើរជាមួយ និងក្រុមខ្លួននោះពេលនេះគេអាចរកឃើញលោករ៉ាទូ និងរកឃើញឥន្ទប្បដិមានោះហើយឬនៅ?

នៅក្នុងផ្ទះឈើតូចមួយដែលជាកម្មសិទ្ធិរបស់បុរសទាបកន្តុលឈ្មោះរ៉ាទូ លំអងកំពុងបញ្ចេញដោយចំហនូវភាពទោមនស្សរបស់ខ្លួន ចំពោះសកម្មភាពចំពោះមុខនៃសង្សារបណ្តូលចិត្ត។

នាងក្រពាត់ដៃបែរខ្នងជាសញ្ញាបដិសេធចំពោះផែនការថ្មីរបស់នាយKen៖

-បងឆ្កួតតែម្នាក់ឯងទៅ! ខ្ញុំមិននៅឆ្កួតជាមួយទេ! ខ្ញុំអត់មានត្រូវការរបស់នោះទេ របស់អីក៏របស់ទៅ ខ្ញុំមកតាមបងដល់ទីនេះ ព្រោះចង់គាំទ្រការងារបង តែអត់មានន័យថា សូម្បីតែលះបង់ខ្លួនក៏ខ្ញុំត្រូវតែធ្វើនោះទេ! អស់សំណើចណាស់ លោកKenលោកអ្នកមានធំ! សូម្បីសង្សារខ្លួនឯងក៏ចង់លើកប្រគេនគេដែរ ដើម្បីអី? ដើម្បីតែវត្ថុដែលបានត្រឹមឮគេនិយាយមិនដែលឃើញរូបរាងពិតហ្នឹង?

នាយKenដែលក្រពុលមុខ ប្រឹងលួងនាងកំណាន់តិចៗ៖

-តែម្តងតើ! មានអ្នកណាដឹង? អូនឯងទៅជាមួយវាតែម្តងទៅ! បងមិនប្រកាន់ទេ! ព្រោះអូនលះបង់ដើម្បីបង! បងពិបាកយ៉ាងណាទម្រាំតាមមកដល់ដំណាក់កាលនេះ បន្តិចទៀតឥន្ទប្បដិមាធ្លាក់ដល់

ដៃយើងហើយ! មួយដង្ហើមទៀតទេ! អ្វីៗបានសម្រេចអស់ហើយ! យើងចង់បកក្រោយទាំងអញ្ចឹងមិនកើតទេ! ណ៎ា!? លំអង? ចាត់ថាធ្វើដើម្បីបងទៅចុះណ៎ា? បងសូមអង្វរ! ណ៎ា! ធ្វើដើម្បីបង!

លំអងងាកមកខ្វាច់។ នាងសម្លឹងមុខពាណិជ្ជករមិនស្មោះស្នេហ៍ហើយសង្កត់ពាក្យធ្ងន់ៗទៅរកគេះ

-Ken! បងមើលមុខខ្ញុំឲ្យច្បាស់! ខ្ញុំមិនមែនកេតឌីម៉ាទេ! បងកុំមកលេងស្បៀតនេះជាមួយខ្ញុំ! អាល្បែងយកប្រៀបលើស្រីៗរបស់បងឯង ល្មមឈប់ប្រើហើយ! បើបងឯងគ្រាន់បើមែន រកវិធីទិញវត្ថុបុរាណនោះដោយសមត្ថភាពខ្លួនឯងទៅ! ក្រែងបងឯងមានលុយមិនខ្វះហ្អី? បងឯងដល់ថ្នាក់ហ៊ានប្រជែងជាមួយកូនប្រុសសភាតំណាងរាស្ត្រចេញមុខ ចាំបាច់អីបងឯងមកយកស្រីៗជាខែលរហូតអញ្ចឹង?

ត្រូវពីរបីឆ្មោងធ្ងន់ៗ ពាណិជ្ជករសុភាពបុរសក្នុងស្រោមក៏កើតក្ដីក្ដៅក្រហល់ក្រហាយពេញបន្ទុក គេលើកកែវភេសជ្ជៈដែលត្រូវបានរៀបទុកជាស្រេចដោយម្ចាស់ផ្ទះលើកូនតុពីមុខខ្លួន ហើយអកក្អឹកបំបាត់កំហឹង និងភាពអាម៉ាស់។

តាមពិតតាំងពីដើមដល់ចប់ ពាណិជ្ជករដែកថៃបមិនដែលមាននារីណាម្នាក់ក្នុងបេះដូងទេ តែនាងៗគ្រាន់តែមកឡូកឡំក្នុងជីវិតនាយដើម្បីជួយសម្រេចផែនការមួយចំនួនដែលនាយ និងទ្រព្យសម្បត្តិនាយមិនអាចធ្វើបានប៉ុណ្ណោះ។ ពីដំបូងឡើយលំអងក៏ភ័ន្តច្រឡំដែរថាបុរសចិត្តមិនស្មោះនេះបោកចិត្តកេតឌីម៉ាដោយសារនាងជានារីល្ងង់ខ្លៅ មិនមែនជានារីដែលគេស្រលាញ់ ហើយស្រីដែលមានតម្លៃសម្រាប់បេះដូងគេគឺមានតែខ្លួនម្នាក់គត់តែដល់ពេលភពប្រសប់គ្នាយូរទៅនាងកាន់តែរកឃើញការពិតដែលថា នាយKen ក៏មាននាងនៅជិតដើម្បីតែផលប្រយោជន៍លើគម្រោងការណ៍ឥន្ទប្បដិមារបស់គេតែប៉ុណ្ណោះ។ ចុងក្រោយទៀតនេះ ពេលបានមកជួបបុរសឈ្មោះវ៉ាទូនៅកោះស្មៅលឿងនេះ បុរសទាបកន្ទុលដ៏ក្រអឺតក្រអោងដែលអួតថាខ្លួនមានឥន្ទប្បដិមាក្នុងដៃដោយទាមទារទឹកប្រាក់ខ្ពស់ហួសហេតុធ្វើអោយពាណិជ្ជករដែកថៃបចង់លេងផ្លូវកាត់វិញដើម្បីអោយដឹងច្បាស់មុនទម្លាក់លុយទៅថាតើរបស់នោះពិតរឺក្លែងក្លាយ។

ហេតុតែចង់សម្រេចបំណងក្នុងការយកឥន្ទប្បដិមាមកគ្រប់គ្រងឲ្យខាងតែបាន គេក៏សុខចិត្តមកអង្វរលំអងឲ្យទៅវាយងន្ទាក់ស្នេហ៍លើបុរសដែលមិនដែលមានស្រីស្អាតនោះ ធ្វើឲ្យនាងយល់ច្បាស់ពីសន្ដានចិត្តគ្មានភាពភក្ដី និងគ្មានការទទួលខុសត្រូវរបស់នាយ។

បានហារស្ដីប្រមាថប្រុសបញ្ញើក្អែកហើយ នារីដែលកំពុងខកចិត្តស្ទុះដើរចេញពីទីនោះទាំងកំហឹង តែនាងត្រូវបានបុរសមានល្បិចទាញមកវិញទាំងប្រផាប់ប្រភីង។ បុរសដែលត្រូវបានគេវែកមុខ និង

កំពុងតែស្ថិតនៅក្នុងស្ថានភាពអន្ទះសាចង់បានឥន្ទប្បដិមាឥតគិតច្រើនទេ គេមានតែផ្លូវចុងក្រោយ គឺបង្ខំឲ្យស្រីស្នេហ៍ដែលដឹងពីមុខមាត់ពិតខ្លួននេះសមតាមបំណងឲ្យខាងតែបាន។

គេសម្លុតនាងដោយទឹកមុខម៉ឺងម៉ាត់៖

-ចង់ទៅណា? កុំនិយាយថា នាងនឹងធ្វើឲ្យគម្រោងការចុងក្រោយរបស់ខ្ញុំត្រូវរលាយណ៎ាលំអង?

លំអងងាកមកវិញដោយរលាស់ដៃនាយចេញ នាងបញ្ចេញភាពមាំទាំតបតមិនចុះញ៉ម។ បបូរមាត់នាងផ្ទុះទន្ទឹមគ្នានូវវាចាអសុរស៖

-ខ្ញុំអត់ខ្វល់ទេ! គម្រោងការអី? លោកឯងបោកប្រាស់ខ្ញុំ ?បង្ខំគ្រប់គ្នាឲ្យមកកោះនេះទាំងព្យុះទាំងភ្លៀងរហូតដល់លិចទូកសឹងស្លាប់ទាំងខ្លួនទៀត ឥឡូវកូនចៅលោកឯងបាត់ខ្លួនអស់ក៏មិនរវល់រកគ្នា ចុងក្រោយសល់តែពីរនាក់ហើយនៅតែមិនភ្ញាក់កំណើត លោកឯងកុំសង្ឃឹមថាខ្ញុំល្ងង់ធ្វើជាអាយ៉ងឲ្យលោកឯងញាក់តាមចិត្តទៀត! មនុស្សបោកប្រាស់!

នាងចាកចេញសាជាថ្មី ធ្វើឲ្យពាណិជ្ជករដែលពុះពោរដោយកំហឹងប្រឹងលូកទាញនាងមកវិញ ហើយលើកដៃម្ខាងច្របាច់កនាង។ ដៃម្ខាងចង្អុលមុខដោយអាកប្បកិរិយាហិង្សា ៖

-ស្តាប់ណ៎ាលំអង! ទោះចង់ក៏ដោយ មិនចង់ក៏ដោយ នាងគ្មានជម្រើសទេ! នាងចេញពីកោះនេះមិនបានដាច់ខាតមុនពេលយើងបានរបស់នោះ! បើចង់មានជីវិតត្រឡប់ទៅផ្ទះ  ត្រូវធ្វើតាមយើងទាំងអស់! ឲ្យចេះប្រើខួរក្បាលផង! ស្មានថាខ្លួនឯងហ្នឹងល្អណាស់ទៅ? បើយើងនេះជាមនុស្សបោកប្រាស់ ចុះខ្លួននាងជាស្អីដែរ? ក្រែងបានបោកប្រាស់មិត្តភក្តិដែរតើហ្អី? ហើយក៏ជាស្រីរបស់អាមនុស្សបោកគេនេះដែរ មែនទេ? កុំបាច់មកចង់លេងល្បែងឆ្កិនភ្នែកធ្វើល្អ ធ្វើត្រឹមត្រូវអី! បើវាធ្លាប់ទៅហើយ ប្រុសម្នាក់ ឬក៏ពីរនាក់ វាមានទៅខុសគ្នាអី?

ស្រីបង្ហាញម៉ូតដែលខកចិត្តផង ឈឺចាប់ផង រើពីការក្របួចរបស់នាយ ហើយឱនលើកកែវភេសជ្ជៈមួយកែវទៀតដែលនៅសល់លើតុ ជះវ៉ាវសំដៅមុខបុរសគ្មានសីលធម៌។ នាងក្តាប់មាត់ដៀល៖

-មនុស្សថោកទាប!

នាយKenហៀបនឹងស្ទុះមករកលំអងជាលើកទី២ ប៉ុន្តែប្រែទៅជាទ្រេតទ្រោតរកកលដួល។ លំអងសម្លឹងទៅជននោះដោយភិតភ័យលាយងឿងឆ្ងល់ ព្រោះថានៅពេលពាណិជ្ជករដែកថៃបបញ្ចេញសារជាតិពិតមកហើយ គេចង់បង្ខំនាងឲ្យទៅប្តូរកិត្តិយសដើម្បីឥន្ទប្បដិមារបស់គេនោះ នាងដឹងថានាងកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារថានៅកោះស្មៅលឿង នាងអត់មានស្គាល់អ្នកណា

ទាំងអស់។ គាប់ជួនបុរសឈ្មោះរ៉ាទូក៏ហាក់មានប្រវត្តិអាក្រក់ច្រើនជាងល្អ ចំណែកអ្នកដែលនាងខំស្រលាញ់ ក៏មានចេតនាទុច្ចរិតលើកនាងឲ្យទៅគេផង តើនាងមានវិធីឯណាអាចយករួចខ្លួនបាន មានតែមធ្យោបាយរត់គេច។លុះឃើញនាយKenស្ទុះមកជាលើកទី២ ប៉ុន្តែបែរជាទ្រេតទ្រោតផេងផោងបន្ទាប់មកទន់កក្បៀកដួលដេកទៅលើសាឡុង នារីកាន់តែងឿងឆ្ងល់។

នាងភ័យផង ឆ្ងល់ផងដោយសារឃើញបុរសចិត្តលោភ ហាក់ដូចជានៅស្ងៀមលែងកម្រើក។ ទឹកមុខរបស់គេមិនសមថាកំពុងលេងល្បិចនោះទេ។ នាងឈានចូលទៅអង្រួននាយKenតិចៗ តែគេមិនត្រឹមតែមិនកម្រើក ប៉ុន្តែបែរជាធ្លាក់ដៃស្ពាកដូចមនុស្សត្រូវថ្នាំសន្លប់។

លំអងបើកភ្នែកធំៗហើយឈានថយក្រោយក្រាកៗ។ នាងឱនមើលកែវទទេដែលនៅជាប់លើដៃខ្លួននៅឡើយ ដោយដណ្ដឹងសួរខ្លួនឯង៖

"ស្អីគេ? គ្រាន់តែជះស្រាដាក់មុខ ដួលសន្លប់ឈឹង?"

ភ្លាមនោះនឹកឃើញដល់រឿងមួយនាងក៏ស្លីគ្រាប់ភ្នែកដោយភិតភ័យ។ នាងចាប់ផ្ដើមយល់ហើយថាដែលមានឥទ្ធិពលរហូតដល់ផ្ដួលរាងកាយពាណិជ្ជករកូនកាត់ឲ្យដួលសន្លប់ឈឹង ប្រាកដជាស្រាក្នុងកែវនេះត្រូវបានលាយថ្នាំសន្លប់ តែមិនមែនស្រានាងទើបនឹងជះនាយទេ គឺស្រាដែលនាយKenលើកក្រេបមុននេះទើបតែសាយភាយ។

ចុះតើអ្នកណាជាអ្នកដាក់ថ្នាំសន្លប់ក្នុងកែវ? ហើយតើគេដាក់ក្នុងគោលបំណងយ៉ាងណា?

ខ្វាយ! ស្រីឆ្លាតទម្លាក់កែវទៅលើកម្រាលឥដ្ឋដោយមិនដឹងខ្លួន ។ ប្រហែលជាសំឡេងបោកទង្គិចនេះបានធ្វើឲ្យលាន់ឮដល់អ្នកផងហើយបានជាលំអងឮស្នូរជើងមនុស្សលាន់មកប្រើបៗ។ ក្នុងគ្រាប្រចុចញ៉ុចនាងមិនដឹងត្រូវធ្វើយ៉ាងណា ក៏ទម្លាក់ខ្លួនលើសាឡុងម្ខាងទៀតធ្វើជាសន្លប់ក្លែងក្លាយ។ ទន្ទឹមនឹងពេលនឹកសរសើរសំណាងខ្លួនឯងដែលមិនក្រេបជាតិស្រាលាយថ្នាំនោះ នារីបង្ហាញម៉ូតទៅជាភ័យញ័រទ្រូងដោយសារស្នូរទ្វារត្រូវរុញរបើកចូលមកតិចៗដូចការស្មានរបស់នាងមែន។

ទោះបីមិនហ៊ានបើកភ្នែក តែដង្ហើមមនុស្សចំណូលថ្មីបានធ្វើឲ្យលំអងអាចទាយដឹងថាពួកគេមានគ្នាលើសពីម្នាក់ច្បាស់ណាស់។

"យើងមកទិញរបស់សោះ ហេតុអ្វីគេចាំបាច់ប្រើវិធីនេះ? ឬមួយគេមិនចង់បានប្រាក់?"

ក្នុងពេលនាងប្រឹងទប់ចិត្តសឹងថាមិនហ៊ានដកដង្ហើម នាងឮសំឡេងបុរសឈ្មោះរ៉ាទូលាន់ឡើងរអ៊ុះៗភាសាបាហាសា (ភាសាប្រើជាទូទៅនៅឥណ្ឌូណេស៊ី និងប្រទេសមួយចំនួនទៀត) ដែលនាង

មិនអាចស្តាប់យល់មួយឃ្លាឡើយ។ បន្ទាប់មកនាងទទួលអារម្មណ៍ថាមានដៃអ្នកណាម្នាក់លូកមកលើកត្រកងនាងចេញទៅ។ ក្លិនប្រេងដូងឆ្អួលលើខ្លួនម្នាក់នោះធ្វើឲ្យនារីដឹងច្បាស់ថា គេនោះជាមនុស្សរស់នៅលើកោះនេះ ដែលកាលពីមកដល់កាលណានាងសម្គាល់ឃើញថាភាគច្រើននៃពួកគេប្រើប្រេងនេះ ដើម្បីធ្វើឲ្យរលើបស្បែក។ ទោះបីមិនដឹងពីគោលបំណងរបស់ពួកគេ ប៉ុន្តែវិធីដាក់ថ្នាំសណ្តំមិនមែនជាវិធីសុចរិតត្រឹមត្រូវទេ។

លំអងសម្ងំ ប៉ុន្តែនាងដឹងថាគ្រោះថ្នាក់កំពុងនៅជិតបង្កើយ តែនាងបានប្រាប់ខ្លួនឯងថា នាងចាំបាច់ត្រូវធ្វើអ្វីម្យ៉ាង ដើម្បីសង្គ្រោះជីវិត។ នាងត្រូវបានគេដាក់សាជាថ្មីទៅលើទីរាបស្មើតែរលោងមួយ ហើយដែលនាងអាចកាត់ស្មានដឹងថាជាគ្រែរនាបឈើ។

…………

រាត្រីកាលឈានចូលសាជាថ្មីលើទន្លេម៉េមប៊ីរ៉ាម៉ូ។ ប្រផ្នូលធ្លាក់ចានពីដៃរបស់កេតឌីម៉ា បាន ធ្វើឲ្យនាងនៅឈរទ្រឹងក្នុងបន្ទប់បាយដោយទឹកមុខត្រិះរិះ។ ទោះបីពេលនេះយល់ថាខ្លួនមានសុវត្ថិភាពដោយបានចេញឆ្ងាយពីភូមិភូវីខាន់ហើយក៏ដោយ ប៉ុន្តែដំណើររុលទៅមុខបន្តរបស់រាមនរិន្ទ និងហេតុការណ៍អាក្រក់ៗដែលកើតមានឡើងជាបន្តបន្ទាប់កាលពីម្សិល បានធ្វើឲ្យនាងនៅតែកើតពិភាល់។

នាងអង្គុយចុះថ្នមៗហើយលូកដៃប្រមូលអំបែងចានទុកដាក់ក្នុងធុងកាកសំណល់ មុនពេលចាកចេញមករកបុរសម្ចាស់ចិត្តនៅខាងក្រៅឃ្លុបកប៉ាល់។

នៅក្រោមពន្លឺចន្ទខៀវស្រអាប់ នាងឃើញបុរសមាឌធំកំពុងឈរសម្លឹងទៅរកផ្ទៃទឹកដែលងងឹតគ្មានទិសតំបន់។ ប្រាកដណាស់ថាគេមិនមែនកំពុងគយគន់ទិដ្ឋភាពដែលគួរឲ្យព្រឺខ្លាចនោះទេ ប៉ុន្តែគឺគេដូចជាកំពុងត្រិះរិះពីរឿងស្មុគស្មាញអ្វីមួយ។

ឈរពីក្រោយខ្នងនាយឆ្ងាយប្រមាណបីជំហាន នាងនឹកទៅដល់សម្តីគេនៅឯផ្ទះសំណាក់ចម្ការត្របែក *"នោះជាពាក្យសន្យារបស់លោកពុកចំពោះដូនតាជំនាន់មុន ហើយពេលនេះវាក្លាយជាពាក្យសន្យារបស់បងទៀត! បងមិនទុកបន្ទុកនេះ តរហូតដល់កូនយើងទេ!"*

ឌីម៉ាដឹងថា ការតាមរកឥន្ទប្បដិមាមិនមែនជាមហិច្ឆតារបស់គេទេ តែជាកាតព្វកិច្ច។ នាងដកដង្ហើមធំ ធ្វើឲ្យនរៈងាកមកសម្លឹង។ គេញញឹមទទួលស្រីស្រស់ដែលបោះជំហានមកសន្សឹមៗ។ នាងនិយាយដោយសម្លឹងចំកែវភ្នែកស្លូតបូតរបស់គេ៖

-ខ្ញុំក៏គេងមិនលក់ដែរ ម៉េចមិនហៅមកឈរជាមួយគ្នាផង?

បុរសលូកដៃក្រសោបចង្កេះស្រីតូចហើយបំបែរប្រាណនាងមកកាន់ពន្លឺពណ៌ខៀវស្រពិចស្រពិលនៅលើផ្ទៃរលក។

"ពីរបីម៉ោងទៀតនេះ យើងអែបចូលកោះស្មៅលឿងហើយ!"

ភាគទី៤០

អ្នកគ្រូបង្ហាញម៉ូតតបវិញ៖

-ហើយលោកក៏គួរតែសប្បាយចិត្តមែនទេ?

រាមនរិន្ទឱនមកសម្លឹងស្រីស្នេហ៍ដែលនៅក្បែរទ្រូង គេនិយាយស្រាលៗ៖

-អត់ទេ! មានតែពិបាកចិត្ត!

ឌីម៉ាសើចយ៉ីះចំអកឲ្យនាយ នាងនិយាយលេបខាយ៖

-សូម្បីអ្នកប្រុសធំរាមនរិន្ទ ក៏ចេះនិយាយពាក្យថាពិបាកចិត្តដែរហ្ន៎ ចុះទម្រាំមនុស្សម្នា?

បុរសសង្ហាដឹងថាកញ្ញាលលេង គេក៏តបវិញតិចៗមិនបង្អង់៖

-ត្រូវហើយ! គឺចាប់ពីចេះស្រលាញ់ស្រី ក៏ចាប់ចេះពិបាកចិត្ត!

នារីសើចក្អាប់មាត់ដោយទឹកមុខម៉្ញិកម៉្ញក់ ក្នុងភាពជានារីដែលកំពុងចុះចាញ់មន្តស្នេហ៍មនុស្សក្បែរខ្លួន។ នាងស្ដីតបពីនាយ៖

-ហើយចុះស្រីនោះនៅឯណា? បើគេធ្វើឲ្យពិបាកចិត្ត ទ្រាំស្រលាញ់គេធ្វើអី?

រាមនរិន្ទមិនចុះញ៉ម គេតបវិញដោយសម្លឹងទៅទីផ្សេងធ្វើហី៖

-ទើបតែស្គាល់បានមួយថ្ងៃ ហើយស្គាល់តាមFacebookទៀត គេមិនទាន់យល់ចិត្តយើង បានជាយើងត្រូវមកពិបាកចិត្ត!

មិនខ្វល់ថាគេនិយាយលេង ឬនិយាយមែនទេ ប៉ុន្តែមុននេះគេទើបតែដើរចេញពីកុំព្យូទ័រមកមែនម្លោះហើយនាងទទួលអារម្មណ៍តូចចិត្តដោយឯកឯង និមិត្តតែឮសម្ដីបញ្ឆោះបន្សោកនេះ។ ស្រី

រលាស់ដៃនាយចេញពីចង្កេះ ដោយងង៉ក់ តែបុរសស្រោក់ចង្កេះនាងដោយដៃទាំងពីរ មិនខ្វល់នឹងមុខរបួសលើទ្រូងឡើយ។

គេនិយាយបកមករកបញ្ហាចំពោះមុខវិញម្តង៖

-បងមិនចង់ឲ្យអូនមកតាមទេ! ពិបាកចិត្តព្រោះអូនមិនព្រមត្រឡប់ទៅចាយ៉ាពូរ៉ាមុន! នារីដឹងថាកោះស្មៅលឿងដែលចូលកាន់តែកៀកនេះក៏មិនដឹងថានឹងមានឧបសគ្គអីខ្លះ ម៉្លោះហើយបានជាគេស៊ូមកឈរពិបាកចិត្តស្ងាត់ៗម្នាក់ឯង។

តរុណីនិយាយតិចៗតប៖

-ខ្ញុំមិនធ្វើឲ្យលោកពិបាកទេ!

នរៈចោទសួរមកវិញភ្លាម៖

-និយាយអញ្ចឹងមានន័យថាម៉េច?

ស្រីស្រស់ចំអន់៖

-គឺពេលលោកឡើងគោក ខ្ញុំនឹងត្រឡប់ទៅវិញម្នាក់ឯង! ហើយចង់ទៅជួបអ្នកFacebookណាក៏តាមចិត្ត!

រាមនរិន្ទសើចក្តាប់មាត់ គេបំបែរស្រីស្អាតមកចំពីមុខខ្លួន រួចជួយលើកដៃផាត់សក់ឲ្យនាង។ គេសម្លឹងផ្ទៃមុខដែលប្រែទៅជាថ្លារលោងដោយសេចក្តីស្នេហា និងការពេញចិត្តពេញថ្លើម។ អ្នកដឹងថា ស្រីម្នាក់នេះក៏ធ្លាក់ក្នុងអន្លង់ស្នេហ៍ដែលអ្នកបានធ្លាក់ចូលទៅមុននេះដែរ គ្រាន់តែមិនទាន់ដឹងថានាងធ្លាក់ជ្រៅ ឬរាក់តែប៉ុណ្ណោះ។ បុរសអភិជនគន់កែវភ្នែករលើបរលោងដែលកំពុងសម្លឹងមកស្នាមញញឹមអំនួតលើបបូរមាត់អ្នក។ នរិន្ទវាចាស្រាលៗបង្អួតសព្ទសូរស្រទន់៖

-ក្នុងជីវិតនេះ រាមនរិន្ទមានក្តីស្រមៃធំបី!

ស្រីស្អាតសើចខឹកម្តងទៀត នាងខ្ទប់មាត់សើច។ ប្រុសស្អាតធ្វើឡិងឡង់ហើយសួរវិញមួយរំពេច៖

-មានអីគួរឲ្យសើច?

កល្យាណក្តាប់មាត់សើចដោយមិនចោលស្នាមញញឹម នាងឧទាន៖

-ដូចលោកហ្នឹងក៏មានក្តីស្រមៃដែរ?

បុរសលើកចិញ្ចើមដោយទឹកមុខអស់សំណើច អ្នកសួរវិញខ្សឹបៗ៖

-អ្នក! អញ្ចឹងគេមិនមែនមនុស្សដូចយើងទេ? ចាត់ទុកថាគេជារុក្ខជាតិ  ជាខ្មោច ឬជាស្អី?

ស្រីស្អាតឃើញបុរសដែលធ្លាប់តែមានអំណាច និងមានបរិវារតាមយកចិត្តឆ្វេងស្តាំឥឡូវមកបាក់ស្លាបធ្វើទឹកមុខគួរឲ្យអាណិតនៅចំពោះមុខខ្លួន នាងអស់ពីចង់សើចទៅជាក្តុកក្តួលចិត្ត។ កេតឌីម៉ាលើកហត្ថទាំងទ្វេឱបរាងកាយរបស់បុរសសង្ហាដែលនៅចំពោះមុខខ្លួន ហើយផ្តេកក្បាលទៅលើដើមទ្រូងនាយ។

"នេះឬមនុស្សស្រី? នាងដូរអារម្មណ៍បានតែត្រឹមមួយប៉ប្រិចភ្នែក? តែភាពរញ៉េរញ៉ៃរបស់នាងហ្នឹងហើយ ដែលធ្វើឲ្យប្រុសៗត្រូវឆ្កួតវង្វេង។"

កូនប្រុសអ្នកនយោបាយនិយាយតិចៗបន្ត៖

-ហើយចង់ដឹងទៀតអត់អញ្ចឹង?

មាណវីនិយាយតបវឹង៖

-ក្តីស្រមៃលោក គឺឥន្ទប្បដិមា!

ប្រអប់ដៃបុរសអង្អែលកេសានាងថ្នមៗ គេសួរនាង៖

-ចុះទី២?

កេតឌីម៉ាគិតបន្តិចទើបឆ្លើយ៖

-លោកចង់ក្លាយជាអ្នកនយោបាយមែនអត់?

រាមនរិន្ទមិនបញ្ជាក់សំនួរនាង បែរជាសួរបន្ថែម៖

-ចុះទី៣?

នាងរវើ្ភកគិត។ "បំណងប្រាថ្នាទី៣របស់គេអាចជារឿងមនោសញ្ចេតនារបស់សត្វលោកដែរអត់? គេមើលទៅក៏មានមនោសញ្ចេតនាណាស់ដែរ តែពេលខ្លះ គឺដាច់ណាត់ណាស់! ស្មានម៉េចហ្នឹងត្រូវទៅ? ចំណែករឿងស្រីៗ តើគេទៅខ្វះអីនោះ? "

នឹកមកដល់ត្រង់ណេះនាងចាប់ផ្ដើមគិតអនិច្ចាចំពោះខ្លួន ភាពកក់ក្ដៅក្នុងរង្វង់ទ្រូងនាយ ធ្វើឲ្យនាងកាន់តែបារម្ភថា ប្រសិនបើគ្មានគេវិញ តើនាងអាចភ្លេចគេបានដោយវិធីណា? នាងដកដង្ហើមធំរួចទើបនិយាយ៖

-ឈប់ទាយហើយ!

រាមនរិន្ទបន្តឹងដៃឱបនាងណែនជាងមុនក្នុងពេលសន្សើមរាត្រីចាប់ផ្ដើមធ្លាក់។ គេនិយាយខ្សាវៗ៖

-ទាយទៀតទៅ ព្រោះអាពីរខាងលើ  និយាយខុសអស់ហើយ! មិនដែលថា មនុស្សស្រលាញ់គ្នាអត់មានយល់ចិត្តគ្នាសូម្បីតែបន្តិចនោះទេ!

នារីញញឹមដោយកក់ក្ដៅក្នុងរង្វង់ដៃគេ នាងពោលតបស្រាលៗ៖

-អាថ៌កំបាំងម្លឹងៗ ពីណាគេទាយត្រូវទៅ?

នរៈសម្លឹងទៅផ្ទៃទឹកដែលស្ងប់ស្ងាត់ក្រោមស្រមោលរាត្រីកាល។ អ្នកពោលតិចៗក្បែរត្រចៀកស្រីស្រស់៖

-និយាយអាទី៣ទៅ!

នាងបានឱកាសមិនព្រមឆ្លើយបែរជាសួរគេវិញ៖

-មិនដឹងថា រាមនរិន្ទមានក្ដីស្រមៃ ចង់បានស្នេហាពិតដែរអត់ទេ?

បុរសឈ្មោកផ្អឹបបបូរមាត់លើកេសាក្រអូបប្រហើររបស់នាង។ គេនិយាយតបតិចៗល្មមតែឮពីរនាក់៖

-គឺបងចង់បានខ្លាំងណាស់!

នារីញញឹមក្នុងរង្វង់ដៃនាយដោយរំភើបចិត្ត។ សំឡេងនរិន្ទលាន់មកបន្ត៖

-ក្ដីស្រមៃទី៣ អូនទាយត្រូវហើយកេតឌីម៉ា!

ប៉ុន្តែនឹកឃើញដល់រឿងផ្សេង នាងបែរជាស្រងូតវិញ។ ភាពសុខសាន្តច្រើនប៉ុណ្ណាពេលបាត់បង់ទៅក៏នឹងនាំចិត្តកាយ ឲ្យពិបាកប៉ុណ្ណឹងដែរ។ ស្រីបង្ហាញម៉ូតបន្ថែមសំនួរថ្មី៖

-សម្រាប់លោក អ្វីទៅជាស្នេហាពិត?

កូនប្រុសអ្នកនយោបាយញញឹមហើយឈ្ងោកសម្លឹងប្រាណស្រីក្នុងរង្វង់ដៃ៖

-គឺដូចពេលនេះអញ្ចឹង! យើងនៅជាមួយគ្នា គឺមានសុភមង្គលដូចបក្សីមួយគូដែលមានសេរីភាព និងហោះចុះឡើងក្បែរៗគ្នា អត់មានអ្នកណារវល់ជាមួយពួកយើងទេ!

ស្រីស្អាតឈ្ងោកមុខដោយពិបាកចិត្ត។ កាន់តែសោយសុខ នាងកាន់តែត្រៀមខ្លួនទទួលយកការបាត់បង់។ គេជាបុរសលើបុរស គេជាកូនប្រុសអ្នកនយោបាយ និងជាមនុស្សប្រុសមានសមត្ថភាពដែលនារីជាច្រើនប្រាថ្នាចង់បាន តើគេអាចនាំនាងឲ្យហោះទៅលើមេឃតែពីរនាក់ដោយគ្មានអ្នករំខានដោយវិធីណាទៅ?

នាងនិយាយតិចៗ៖

-ចុះបើមានស្នេហាពិតហើយ លោកមានវិធីថែទាំរបស់នោះអត់? លោកមិនមែនសត្វបក្សាទេ ហើយក្រៅពីស្នេហា លោកនៅមានក្តីស្រមៃពីរទៀតដែលត្រូវបំពេញទៀតមែនអត់?

នាងសួរដោយអស់សង្ឃឹម តែគេឆ្លើយវិញដោយមិនទាក់ទើរ៖

-អញ្ចឹងហើយបងត្រូវធ្វើការងារពីរនោះឲ្យរួចដាច់ខាត មុនពេលប្រើជីវិតនៅសល់របស់បងជាមួយក្តីស្រមៃទី៣ហ្នឹង!

ស្រីស្អាតបេះដៃគេចេញពីចង្កេះ នាងបែរទៅរកគេជាមួយទឹកមុខស្ងួតស្ងប់។ នាងនិយាយដោយសម្លឹងភ្នែកគេ៖

-យូរប៉ុណ្ណាទៅ?

រាមនរិន្ទសម្លឹងតបមកនាង បបូរមាត់ស្រស់សង្ហាវាចាតបស្រាលៗ៖

-បីឆ្នាំ!

ឃើញនាងនៅសម្លឹងគេភ្លឹកភ្លាំងមិនមានប្រតិកម្ម ប្រុសស្អាតនិយាយបន្ថែម៖

-ចាំបង! ហើយស្មោះជាមួយបងជានិច្ច បានអត់ឌីម៉ា?

នារីឈ្ងោកមុខគេចេញពីក្រសែភ្នែកគេ។ សំឡេងមួយលេចឡើងក្នុងគំនិតនាងតែម្នាក់ឯង៖

"កុំថាឡើយ៣ឆ្នាំ ទោះបីមួយជីវិតនេះក៏ដោយ ឲ្យតែបានស្នេហាពិតរបស់លោក ខ្ញុំអាចធ្វើអ្វីបានទាំងអស់! នេះជាចរិតរបស់ស្រីល្ងង់កេតឌីម៉ា ដែលតែងតែធ្វើគ្រប់យ៉ាងដើម្បីស្នេហា។"

ឃើញនាងលែងនិយាយស្តី កូនប្រុសតំណាងរាស្ត្រសួរបន្ត៖

-បានអត់?

ស្រីឆ្កួតស្នេហ៍ងើបមុខសួរគេវិញភ្លាម៖

-បន្ទាប់មក យើងលែងបែកគ្នារហូតមែនអត់?

បុរសញញឹមពេលយល់ពីជម្រៅស្នេហ៍នាង។ គេងក់ក្បាលផ្ងក់ៗ៖

-បាទ! រាប់ចាប់ពីយប់នេះទៅ! ៣ឆ្នាំទៀត យើងនឹងនៅជិតគ្នា ធ្វើជាត្រចៀកកាំមួយគូ ហោះចុះហោះឡើងជុំវិញផែនដីនេះ! យើងអាចទៅទីណាក៏បាន តែយើងអត់បែកគ្នាទេ!

នារីសើចខឹក នាងមិនចេញស្តី ធ្វើឲ្យបុរសងឿងឆ្ងល់ សួរបន្ទាន់វិញ៖

-ហើយម៉េច? អត់ជឿ?

នាងឆ្លើយតប៖

-លោកនិយាយដូចក្នុងកុន! លោកសមតែជាអ្នកតែងរឿងស្នេហាទេ!

រាមនរិន្ទសម្លឹងស្នាមញញឹមរបស់នាង សុភមង្គលនាងហាក់កំពុងអណ្តែតឡើងមកតាមពាក្យរៀបរាប់ និងតាមពាក្យសន្យារបស់នាយ។ ស្នាមញញឹមសុខដុមរមនារបស់ស្រីម្នាក់ដែលច្បាំងយកបានសន្តិភាពមកទុកក្នុងបេះដូងនាង ហើយក៏ជាស្នាមញញឹមដែលប្រុសម្នាក់នៅចំពោះមុខនាងប្តេជ្ញាថារក្សាឲ្យនាងជារៀងរហូត។ ប៉ុន្តែមិនទាន់អីផង ស្នាមញញឹមនោះរុះរោយវិញបាត់ទៅហើយ។ ម្ចាស់វាក៏ដកខ្លួនត្រឡប់ទៅឈរនៅទីមួយឆ្ងាយពីនោះដោយផ្តោតសម្លឹងទៅក្នុងទន្លេវិញ។ សំឡេងស្រងូតរបស់នាងលាន់ឮមកក្នុងពេលដែលនរៈដើរត្រឹកៗមកក្បែរ៖

-ប៉ុន្តែចុះបើ៣ឆ្នាំហើយ លោកនៅតែមិនឃើញត្រឡប់មកវិញ?

អនាគតអ្នកនយោបាយបន្លឺតបពីក្រោយខ្នងនាង៖

-អញ្ចឹងយើងធ្វើកិច្ចសន្យាមួយទៅ? អូនក៏ស៊ីញ៉េ ហើយបងក៏ស៊ីញ៉េ! អ្នកណាក្បត់ទំនុកចិត្ត អ្នកនោះមានរឿងធំ!

ស្រីស្លូតត្រង់ងាកក្រោយដោយញញឹមហួសចិត្ត៖

-រឿងធំអីទៅ? និយាយអីក៏ដាច់ណាត់ម្ល៉េះ?

តែគេមិនមែនកំពុងនិយាយលេងដូចដែលនាងកំពុងគិតទេ ព្រោះគេញាក់ចិញ្ចើមផ្ដើននាងពេលនាងសម្លឹងមក វាដូចជាទម្លាប់ញាក់ចិញ្ចើមបញ្ឈឺនាងកាលពីនាងនិយាយមិនឈ្នះគេនៅឯបន្ទប់សណ្ឋាគារកោះបាលី ពេលនោះកូនចៅគេកំពុងប្រដៅអ្នកស្រីកុលាប។ ឫកពាគេពេលនេះដូចជាពេលមុនៗដែរ គឺគ្មានត្រង់ណាបង្ហាញថា គេនិយាយហើយមិនធ្វើនោះទេ។ នាងងក់ក្បាលផ្ងក់ៗផ្ទាន់គេវិញ៖

-មានអី! លោកចុះហត្ថលេខាធ្វើកិច្ចសន្យាទៅ! ខ្ញុំនៅចាំមើល!

-ឯណាក្រដាស? (គេសួរតប)

នាងឆ្លើយធ្វើហី៖

-គឺទន្លេម៉េមប៊ីវ៉ាម៉ូនេះហើយ ជាកុងត្រាស្នេហារបស់ពួកយើង ចំណែកលោកឆាប់ចុះហត្ថលេខាទៅលើមេឃនេះទៅ! ខ្ញុំក៏នឹងធ្វើតាមក្រោយ!

នរៈក្ដុកក្ដួលចិត្តសាជាថ្មី។ នាយសម្លឹងផ្ដោតទៅលើពន្លឺថ្លាឆ្វង់ក្នុងកែវភ្នែកនាងដែលឆ្លុះនឹងពន្លឺព្រះចន្ទ។ តាមពិតកុងត្រាស្នេហាលើទន្លេម៉េមប៊ីវ៉ាម៉ូ និងចុះហត្ថលេខាលើខ្យល់ គឺមានន័យស្រេចហើយថានារីម្នាក់នេះត្រៀមអភ័យទោសឲ្យគេ ទោះគេមិនអាចធ្វើតាមកិច្ចសន្យានេះក្នុងរវាងបីឆ្នាំក្ដី។ នាងប្រហែលគិតថា ការងារធំពីរទៀតអាចជាឧបសគ្គក្នុងការឲ្យគេវិលមកវិញបានក្នុងរវាងពេលត្រឹមបីឆ្នាំ ម្ល៉ោះហើយទោះគេវិលមកវិញមិនបានទាន់ពេល ឬគេមិនវិលមកវិញជារៀងរហូត ដោយប្រការណាមួយក៏នាងនៅតែអភ័យទោសឲ្យគេ។

ឃើញអ្នកប្រុសប្រែប្រួលទឹកមុខទៅជាស្រងូត ស្រីស្អាតប្រឹងញញឹមទៅរកគេកុំឲ្យគេដឹងបានពីជម្រៅនៃទុក្ខកង្វល់របស់នាង ប៉ុន្តែនាងកាន់តែញញឹម ដូចកាន់តែបង្ហាញពីទុក្ខព្រួយក្នុងពន្លឺភ្នែកនាងឲ្យគេឃើញ។ បុរសឱបស្រីម្ចាស់ចិត្តសាជាថ្មីពេញក្នុងរង្វង់ដៃហើយលែងចេញស្ដី។ រាត្រីឈានទៅមុខសន្សឹមៗទុកឲ្យគូស្នេហ៍ទាំងទ្វេសំងំក្បែរគ្នាកណ្ដាលធម្មជាតិស្ងាត់សូន្យដែលហាក់ដូចជាមានចេតនាបង្កើតភាពស្រងេះស្រងោចមកបន្លាចពួកគេ។

ស្នេហាគឺជាទុក្ខព្រួយច្បាស់ណាស់ ព្រោះថាពេលគេមិនទាន់បានវា គេខ្វល់ខ្វាយចង់បានជាខ្លាំង ប៉ុន្តែនៅពេលបានដល់ដៃហើយ គេក៏នៅតែភ័យព្រួយខ្លាចថាជួបគ្នាមិនបានយូរទៀត។

នៅក្នុងបេះដូងបុរសត្រកូលខ្ពស់ គេដឹងច្បាស់ថាគេបានជួបមនុស្សស្រីម្នាក់ដែលគេបានទន្ទឹងរង់ចាំជាយូរមកហើយ ស្រីដែលគេជួបហើយពិបាកភ្លេចនាងបាន និងជាស្រីដែលអាចធ្វើឲ្យបេះដូងគេយល់ពីការឈឺចាប់ និងផ្អែមល្ហែមនៃសេចក្ដីស្នេហាលើផែនដីនេះ។

"នាងគិតថា យើងចង់ក្លាយជាមនុស្សល្បីឈ្មោះ ជាអ្នកនយោបាយ អញ្ចឹងហើយនាងមានរឿងអីសង្ឃឹមថាយើងចាកចេញពីការងារនោះក្នុងរវាងពេលបីឆ្នាំ? នាងយល់ថាចុងក្រោយយើងនៅតែបែកគ្នា តែនាងនៅតែញញឹមលួងចិត្តយើង ព្រោះនាងមិនចង់បង្ខំចិត្តមនុស្សប្រុសដែលនាងស្រលាញ់ឲ្យលះបង់របស់ទាំងនោះដើម្បីស្នេហារបស់នាងទេ! មនុស្សស្រីដូចនាងតើនៅមានសល់ប៉ុន្មាននាក់ទៀតនៅលើផែនដីនេះ? នាងមិនសង្ឃឹមផងថាយើង និងក្លាយទៅជាសត្វត្រចៀកកាំជាមួយនាង តែនាងក៏នៅតែមិនបង្ខំឲ្យយើងសន្យាអ្វីទាំងអស់! ស្រីនេះចំជាឆ្កួតមែនហើយ!" អ្នកប្រុសបណ្ដោយឲ្យពេលវេលាស្ងប់ស្ងាត់រំលងទៅ ព្រោះគេមិនចង់និយាយអ្វីបន្តឡើយក្នុងពេលដែលចិត្តកំពុងរំជួល ប៉ុន្តែបន្តិចក្រោយមកគេចាប់ផ្ដើមវាចាសាជាថ្មី៖

-ឱម៉ា! មនុស្សស្រលាញ់គ្នា ត្រូវជឿជាក់គ្នា ត្រូវទុកចិត្តគ្នា!

ស្រីស្រស់រលីងរលោង នាងងក់ក្បាលផ្ងក់ៗក្រោមលង្វែកទ្រូងនាយ។ ប៉ុន្តែនាងនិយាយប្រាប់ខ្លួនឯងស្ងាត់ៗ៖

"ខ្ញុំជឿបេះដូងលោក! តែជីវិតលោកមិនមែនដើម្បីស្នេហាឡើយ! ហើយខ្ញុំមិនជឿទេ ថាលោកនឹងអាចវិលមករក្សាកិច្ចសន្យាស្នេហារបស់យើង។"